# កំណត់ត្រាសង្ខេប

## ជាកំហុសបច្ចេកវិទ្យា?
## ទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា

ខែកុម្ភៈ ឆ្នាំ២០១៦

## ខ្លឹមសារសង្ខេប

*"អ៊ីនធឺណិតគឺជាឧបករណ៍ដ៏មានឥទ្ធិពលមួយក្នុងចំណោមឧបករណ៍នានា ក្នុងសតវត្សទី ២១ នេះ ដើម្បីបង្កើនតម្លាភាពពីសកម្មភាពរបស់អ្នកមានអំណាច ការទទួលបានព័ត៌មាន និងជួយសម្រួលដល់ការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងការកសាងសង្គមប្រជាធិបតេយ្យ។"*

យោងតាមប្រសាសន៍របស់ លោក ហ្រ្វង់ ឡា រុយ (Frank La Rue) អតីតអ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពខាងការបញ្ចេញគំនិត និងការបញ្ចេញមតិ ("អ្នករាយការណ៍ពិសេស") ខែឧសភា ឆ្នាំ២០១១។

ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") មានការកើនឡើងយ៉ាងលឿន តាមការប៉ាន់ប្រមាណនាពេលថ្មីៗនេះ ចាប់តាំងពីត្រីមាសទីពីរ នៃឆ្នាំ ២០១៥ បានបញ្ជាក់ថាអ្នកប្រើប្រាស់អ៊ីនធឺណិតមានចំនួនជាង ៤១ភាគរយ នៃចំនួនប្រជាជន ដែលជាកំណើនដ៏ច្រើនមួយ បើប្រៀបធៀបទៅនឹងស្ថិតិរបស់ធនាគារពិភពលោកនៅឆ្នាំ ២០១០ ដែលបានបង្ហាញថាការជ្រៀតចូលនៃអ៊ីនធឺណែតមានចំនួនត្រឹមតែ ១.៣ ភាគរយតែប៉ុណ្ណោះ។[1] ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតដែលក្នុងនោះរួមមានអ្នកសរសេរប្លុក អ្នកសារព័ត៌មាន អ្នកចែកចាយព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") សកម្មជន និងនិស្សិតសាកលវិទ្យាល័យបានចាប់ផ្តើមប្រើប្រាស់បណ្តាញអ៊ីនធឺណិតជាពិសេសគេហទំព័របណ្តាញផ្សព្វផ្សាយសង្គមដែលជាឧបករណ៍មួយក្នុងការចែករំលែកព័ត៌មាន និងគំនិតយោបល់ផ្នែកនយោបាយ។ អ៊ីនធឺណិតបានក្លាយជាវេទិកាដ៏សំខាន់សម្រាប់ការជជែកដេញដោលដោយសេរីផ្នែកនយោបាយក្នុងប្រទេសកម្ពុជា ជាកន្លែងដែលប្រជាពលរដ្ឋដែលរងការរំលោភបំពានសិទ្ធិបង្កើននូវសកម្មនិយមនៅលើបណ្តាញអ៊ីនធឺណិតដើម្បីប្រឆាំងនឹងការរំលោភបំពានដែលរីកសាយភាយនិងទាមទារឱ្យមានកំណែទម្រង់នយោបាយ។ ចក្ខុវិស័យរបស់អង្គការ

[1] "អ្នកចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិត" *ប្បញ្ញត្តិករទូរគមនាគមន៍កម្ពុជា។* អាចរកបានតាមរយៈ ៖ http://bit.ly/1mfBlqa.

សង្គមស៊ីវិល("សង្គមស៊ីវិល") គឺការប្រាស្រ័យទាក់ទងគ្នានៅលើបណ្តាញអ៊ីនធឺណិតក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់មួយក្នុងការឃ្លាំមើលសិទ្ធិមនុស្ស និងការបោះឆ្នោត ដែលអាចមានប្រតិកម្មភ្លាមៗទៅលើករណីរំលោភសិទ្ធិមនុស្ស។ កាលពីមុន អ៊ីនធឺណិតជាលំហសេរីមួយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែស្ថានភាពបច្ចុប្បន្ននេះកំពុងទទួលរងការវាយប្រហារលើសេរីភាពភាពអ៊ីនធឺណិត និងសិទ្ធិបច្ចេកវិទ្យាពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល")។ យ៉ាងហោចណាស់មនុស្សចំនួន ៧ នាក់ត្រូវបានចាប់ខ្លួនដោយសារបង្ហោះសារ ឬបញ្ចេញមតិយោបល់តាមបណ្តាញអ៊ីនធឺណិតចាប់តាំងពីខែសីហា ឆ្នាំ២០១៥ កន្លងមក ហើយម្នាក់ក្នុងចំណោមអ្នកទាំងនោះនៅបន្តស្ថិតនៅពន្ធនាគារនៅឡើយ។ ជាងនេះទៅទៀត យ៉ាងហោចណាស់មនុស្សចំនួន ២៣នាក់ត្រូវបានគំរាមកំហែងជាសាធារណៈចាប់តាំងពីខែសីហា ឆ្នាំ២០១៥ ដោយសារការបញ្ចេញមតិយោបល់លើបណ្តាញសង្គម។

ការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតជាមធ្យោបាយបឋមមួយដើម្បីជជែកដេញដោលអំពីនយោបាយគឺជាឱកាស និងជាការគំរាមកំហែងមួយផងដែរដល់ការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលប្រជាជនសាមញ្ញមានឱកាសកាន់តែច្រើន ក្នុងការចូលរួមក្នុងដំណើរការនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការតាមដានខ្លឹមសារដែលបានផ្សព្វផ្សាយលើបណ្តាញអ៊ីនធឺណិតដែលនេះធ្វើឲ្យមានការកើនឡើងនូវការប្រឈមដល់អ្នកដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងផលប្រយោជន៍រដ្ឋាភិបាល ដែលអាចរងការយាយីតាមផ្លូវតុលាការ។ ចលនាឆ្ពោះទៅកាន់វេទិកាលើបណ្តាញអ៊ីនធឺណិតបង្កឲ្យមានការលេចចេញនូវបញ្ហាផ្លូវច្បាប់ស្មុគស្មាញមួយចំនួន ដែលជាញឹកញាប់ពាក់ព័ន្ធនឹងតុល្យភាពដ៏ផុយស្រួយមួយរវាងសិទ្ធិរបស់បុគ្គលខាងការបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត និងការប្រកួតប្រជែងផលប្រយោជន៍ ដូចជាសិទ្ធិឯកជនរបស់អ្នកដទៃ ឬផលប្រយោជន៍របស់សង្គមទាំងមូល។ ខណៈពេលដែលតុល្យភាពនេះត្រូវតែអនុវត្តមួយករណីម្តងៗ លទ្ធផលនៃការឃ្លាំមើលរបស់ ម.ស.ម.ក ក្នុងអំឡុងពេលប្រាំមួយខែ បានបង្ហាញថាសេរីភាពខាងការបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត ជារឿយៗត្រូវបានរំលោភបំពានដោយខុសច្បាប់។

កំណត់ត្រាសង្ខេបនេះនឹងផ្តល់ជូននូវទិដ្ឋភាពទូទៅស្តីពីស្ថានភាពបច្ចុប្បន្ននៃសិទ្ធិ និងសេរីភាពលើបណ្តាញអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា។ **ផ្នែកទី១ អំពីសេចក្តីផ្តើម** ផ្តល់ជូននូវទិដ្ឋភាពទូទៅពីបរិបទនៃស្ថានភាពសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ **ផ្នែកទី២ អំពីក្របខណ្ឌច្បាប់** ផ្តល់នូវការពិនិត្យមើលក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលជះឥទ្ធិពលលើបរិបទបច្ចេកវិទ្យានៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ដោយរួមមានការវិភាគទៅលើច្បាប់ដែលប៉ះពាល់ដោយប្រយោលមកលើសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា ដូចជាបទឧក្រិដ្ឋបរិហារកេរ្តិ៍ និងបទញុះញង់។ **ផ្នែកទី៣ ស្តីពីកម្ពុជា ៖ សិទ្ធិបច្ចេកវិទ្យាក្នុងការអនុវត្តជាក់ស្តែង** បង្ហាញ និងវិភាគទៅលើករណីនៃការរំលោភសិទ្ធិបច្ចេកវិទ្យាមួយចំនួន ដែល ម.ស.ម.ក បានឃ្លាំមើល ចាប់តាំងពីខែសីហា ឆ្នាំ ២០១៥ មក។ **ផ្នែកទី៤ ស្តីពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍** ផ្តល់ជូននូវអនុសាសន៍មួយចំនួន

លើវិធីសាស្ត្រដែលគ្រប់គ្រងបរិយាកាសបច្ចេកវិទ្យាស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

កំណត់ត្រាសង្ខេបនេះត្រូវបានតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។ គម្រោងសិទ្ធិបច្ចេកវិទ្យារបស់ម.ស.ម.ក ("គម្រោង") មានគោលបំណងការពារសេរីភាពលើបណ្តាញអ៊ីនធឺណិត និងបង្កើតយុទ្ធនាការតស៊ូមតិដែលប្រកបដោយប្រសិទ្ធិភាព និងមានទិសដៅក្នុងការធានាថាច្បាប់ដែលបានស្នើឡើងណាមួយក៏ដោយត្រូវធានានូវសេរីភាពលើបណ្តាញអ៊ីនធឺណិតផងដែរ។

## ១.សេចក្តីផ្តើម

ការរីករាលដាលនៃការរំលោភបំពានសិទ្ធិមនុស្ស លំហប្រជាធិបតេយ្យមានការរួមតូចនិងការរឹតត្បិតជាប្រព័ន្ធទៅលើសំលេងជំទាស់ពីសំណាក់រាជរដ្ឋាភិបាល និងការកើនឡើងនៃការរំលោភសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងលំហបច្ចេកវិទ្យាបង្ហាញឱ្យឃើញពីបរិយាកាសនយោបាយនៅកម្ពុជានាពេលបច្ចុប្បន្ននេះ។[2] ក្នុងបរិបទនេះ សកម្មជន និង អ្នកដឹកនាំសហគមន៍ដែលកំពុងក្រោកឈរឡើងដើម្បីទាមទារសិទ្ធិឱ្យប្រជាពលរដ្ឋដទៃទៀតបានប្រឈមនូវហានិភ័យជាពិសេសការយាយីតាមប្រព័ន្ធតុលាការដោយរួមមានការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត និងការកាត់ទោសដោយអយុត្តិធម៌។

ក្នុងប្រទេសកម្ពុជា អ៊ីនធឺណិតនៅតែជាការជជែកវែកញែកថាជាមធ្យោបាយដ៏សេរីបំផុតនៃការសំដែងមតិ និងការចែករំលែកព័ត៌មាន ទោះបីជាស្ថានភាពនេះកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក៏ដោយ។ កង្វះនូវឯករាជ្យភាពក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយតាមបែបប្រពៃណី មានន័យថាអ៊ីនធឺណិតជាវេទិកាដែលមានតម្លៃមួយ ជាក់ស្តែងដោយសារអ៊ីនធឺណិតផ្តល់លទ្ធភាពក្នុងការទទួលបាននូវព័ត៌មានដែលសំបូរបែបពីប្រភពផ្សេងៗ និងមិនលំអៀង ព្រមទាំងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ចូលរួមក្នុងសកម្មនិយមលើបណ្តាញអ៊ីនធឺណិត រៀបចំ និងកៀគរក្នុងការតវ៉ា និងចងក្រងជាឯកសារនៃការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀតផងដែរ។[3] យោងទៅលើរបាយការណ៍របស់អង្គការហ្វ្រីដឹមហាវក្នុងឆ្នាំ២០១៥ "អ៊ីនធឺណិតនៅប្រទេសកម្ពុជាត្រូវបានចាត់ទុកថាមាន" សេរីភាពដោយផ្នែក" ដោយសារ អ៊ីនធឺណិតនៅកម្ពុជានៅមានសេរីភាពនៅឡើយ បើប្រៀបធៀបទៅនឹងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ហើយនេះអាចដោយសារតែត្រូវការធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងធនធានមនុស្សច្រើនដើម្បីគ្រប់គ្រងសេរីភាពនេះ។[4]

---

[2] សម្រាប់ការត្រួតពិនិត្យពិស្តារនៃការគំរាមបច្ចុប្បន្នលើប្រជាធិបតេ្យសូមពិនិត្យមើល "កម្ពុជា៖ លទ្ធិប្រជាធិបតេយ្យកំពុងរងការគំរាមកំហែង" ម.ស.ម.ក (ខែកញ្ញា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1QRhhrw

[3] របាយការណ៍ប្រចាំប្រទេសឆ្នាំ២០១៥ ស្តីពីកម្ពុជា ដោយអង្គការ ហ្វ្រីដឹមហាវ អាចរកបានតាមរយៈ ៖ http://bit.ly/20J8n1a

[4] ដូចខាងលើ។




ស្ថិតិក្នុងឆ្នាំ ២០១៥ បង្ហាញថានគរូបនីយកម្មក្នុងប្រទេសកម្ពុជាមានចំនួន ២០ ភាគរយ ទោះបីជាចំនួននៃការតភ្ជាប់ទូរសព្ទចល័តមានចំនួន ២៤,២លានប្រហែលជា ១៥៧ ភាគរយនៃចំនួនប្រជាជាជនទាំងអស់ក៏ដោយ។[5] ប្រជាជនកម្ពុជាប្រមាណជា ១៦ ភាគរយ (២,៤លាននាក់)ជាអ្នកប្រើប្រាស់បណ្ដាញសង្គមយ៉ាងសកម្ម ហើយភាគច្រើនបំផុតនៃចំនួននេះ (២,២លាន) បានតភ្ជាប់នឹងប្រព័ន្ធផ្សព្វផ្សាយសង្គមនិងបណ្ដាញអ៊ីនធឺណិតដោយប្រើប្រាស់ឧបករណ៍ចល័ត។ [6] របាយការណ៍ចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (“ក.ប.ទ”) នៅក្នុងត្រីមាសទី ២ នៃឆ្នាំ២០១៥ បង្ហាញថាមានអ្នកតភ្ជាប់បណ្ដាញអ៊ីនធឺណិតចំនួនប្រាំលាននាក់នៅក្នុងប្រទេស ដែលភាគច្រើនលើសលប់នៃចំនួននេះ ៩៨,៦៧ ភាគរយបានតភ្ជាប់តាមរយៈឧបករណ៍ចល័ត។[7] តួលេខនេះចង្អុលបង្ហាញពីសក្ដានុពលនៃការជ្រៀតចូលនៃអ៊ីនធឺណិត និងទូរស័ព្ទទំនើប(ស្មាតហ្វូន)ទូទាំងប្រទេស។ កំណើនលទ្ធភាពក្នុងការទទួលបានសេវាអ៊ីនធឺណិតធ្វើឲ្យមានលទ្ធភាពប្រើប្រាស់បណ្ដាញសង្គម ដែលជាឧបករណ៍បឋមសម្រាប់សកម្មនិយមលើបណ្ដាញអ៊ីនធឺណិត។ ប្រទេសកម្ពុជាមានអ្នកប្រើប្រាស់បណ្ដាញហ្វេសប៊ុកប្រមាណ ១.៧៦០.០០០ នាក់ ជាមួយនឹងការកើនឡើងអ្នកប្រើប្រាស់ថ្មីចំនួន ១.១០០នាក់ ជារៀងរាល់ថ្ងៃ។[8] ជាក់ស្ដែង ការប្រើប្រាស់ហ្វេសប៊ុកបានសាយភាយនៅក្នុងកម្ពុជាដែលមន្ត្រីរដ្ឋាភិបាលបានចាប់ផ្ដើមទាញផលចំនេញពីប្រជាប្រិយភាពនេះដោយប្រើប្រាស់បណ្ដាញ

---

[5] ស៊ីម៉ុន កឹម (Simon Kemp) ″បច្ចេកវិទ្យា សង្គម និងចល័តក្នុង អេពិច(APAC) ក្នុងឆ្នាំ 2015″ *យើងជាសង្គម* (ថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/DSMAP15

[6] ដូចខាងលើ

[7] ម៉ារៀ ប៉ូឡា ប្រ៊ីតូ (Maria Paula Brito) និង អួច សូនី “មួយភាគបីនៃប្រជាជនកម្ពុជាប្រើអ៊ីនធឺណិតតាមរយៈទូរស័ព្ទចល័ត″ សារព័ត៌មាន *ខេមបូឌា ដេលី*(ថ្ងៃទី ១២ ខែមិនា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1nKVfKC និង “ពិនិត្យផងដែរ ៖អ្នកចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិត″ *បញ្ញត្តិករទូរគមនាគមន៍កម្ពុជា។* អាចរកបានតាមរយៈ ៖ http://bit.ly/1mfBlqa

[8] កម្ពុជាបណ្ដាញសង្គម ‘នៅកម្ពុជា?′ (២០១៥) http://bit.ly/1nsWk9O

នេះក្នុងការប្រមែប្រមូលការគាំទ្រ និងទទួលមតិយោបល់ពីសាធារណៈជន។ នាយករដ្ឋមន្ត្រី ហ៊ុន សែនបានចូលរួមក្នុងនិន្នាការប្រើប្រាស់បណ្តាញសង្គមដែលមានការកើនឡើងនេះផងដែរ ដោយប្រើប្រាស់គណនីយហ្វេសប៊ុក របស់ខ្លួនយ៉ាងសកម្មក្នុងការឃ្លាំមើលមតិយោបល់លើបណ្តាញអ៊ីនធឺណិតហើយថែមទាំងបង្កើតកម្មវិធី "app" នៅលើស្មាតហ្វូនរបស់លោក សម្រាប់ឱ្យអ្នកប្រើប្រាស់ទទួលបានព័ត៌មានបច្ចុប្បន្នភាពរបស់លោកផងដែរ។

បណ្តាញសង្គមបានក្លាយទៅជាវេទិកាសំខាន់បំផុតសម្រាប់ការបញ្ចេញមតិយោបល់ និងការជជែកវែកញែកអំពីនយោបាយនៅក្នុងប្រទេសកម្ពុជា។ ប្រជាពលរដ្ឋដែលបដិសេធក្នុងការប្រើប្រាស់ការផ្សព្វផ្សាយព័ត៌មានក្នុងការសំដែងការមិនពេញចិត្តរបស់ពួកគេចំពោះការអនុវត្តរបស់រដ្ឋាភិបាល បានងាកមកប្រើប្រាស់បណ្តាញសង្គមវិញ។ និន្នាការនេះមានការផុសផុលយ៉ាងខ្លាំងក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០១៣។ គណបក្សជំទាស់គឺគណៈបក្សសង្គ្រោះជាតិកម្ពុជា ("ក.ស.ជ") បានទាញយកចំណេញយ៉ាងមានប្រសិទ្ធិភាពពីសហគមន៍នៅលើបណ្តាញអ៊ីនធឺណិត ដោយប្រមូលបានការគាំទ្រគួរឱ្យកត់សម្គាល់ក្នុងចំណោមយុវជន និងប្រជាពលរដ្ឋនៅទីក្រុង ដែលនាំឲ្យមានការប៉ះពាល់គួរឱ្យកត់សម្គាល់ខាងផ្នែកនយោបាយដោយសារតែគណបក្សជំទាស់ទទួលបានលទ្ធផលជាងពេលណាៗទាំងអស់ស្ទើរទទួលបានជ័យជំនះ ដោយទទួលបានសំលេង ៥៥ អាសនៈនៅក្នុងរដ្ឋសភាជាតិ។ មួយផ្នែកក្នុងការឆ្លើយតបនឹងលទ្ធផលដ៏គួរឲ្យភ្ញាក់ផ្អើលនេះ និងមួយផ្នែកដោយសារការមិនពេញចិត្តនឹងការកើនឡើងនូវសិទ្ធិអំណាច និងការចងក្រងជាបណ្តាញរបស់ប្រជាលរដ្ឋផងនោះ រដ្ឋាភិបាលបានសម្រេចក្នុងការចាត់វិធានការទប់ស្កាត់លើអ្នកដែលធ្វើការរិះគន់រដ្ឋាភិ បាលតាមរយៈបណ្តាញសង្គម។

កាលពីចុងឆ្នាំ ២០១៤ អង្គភាពសារព័ត៌មាន និងប្រតិកម្មរហ័សរបស់ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រកាសបង្កើត "ក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គម"[9] ក្នុងគោលបំណងធ្វើការឃ្លាំមើលនូវរាល់សកម្មភាពលើបណ្តាញអ៊ីនធឺណិតដើម្បី *"ការពារនូវគោលជំហរ និងកិត្តិស័ព្ទរបស់រដ្ឋាភិបាល"* ខណៈពេលដែលក្រសួងមហាផ្ទៃបានប្រកាសថាក្រសួងនឹងតម្លើងឧបករណ៍តាមដានត្រួតពិនិត្យក្នុងគ្រប់បណ្តាញទូរស័ព្ទចល័ត និងអ្នកផ្តល់សេវាអ៊ីនធឺណិតទាំងអស់ ("ISPs") នៅក្នុងប្រទេសកម្ពុជា ។ បន្ថែមពីលើនេះទៀត សេចក្តីព្រាងច្បាប់ដែលគំរាមកំហែងដល់សិទ្ធិបច្ចេកវិទ្យាត្រូវដាក់ចេញឬស្ទើឡើង ខណៈពេលដែលការអនុវត្តដែលមានការរំលោភបំពានដោយក្រុមព្រហ្មទណ្ឌបានកំពុងក្លាយជារឿងធម្មតាក្នុងការគោរពសិទ្ធិអ្នកប្រើប្រាស់អ៊ីនធឺណិត។

## ២.ក្របខ័ណ្ឌច្បាប់

### ២.១ ការការពារសិទ្ធិមនុស្ស

[9] ម៉ាត់ ប្លូមប៊ើត (Matt Blomberg) និង គុច ណារ៉េន "ក្រុមការងារ ប្រព័ន្ធផ្សព្វផ្សាយសង្គម នឹងគ្រប់គ្រងគេហទំព័រ" សារព័ត៌មាន *ខេមបូឌាដេលី* (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤) អាចរកបានតាមរយៈ ៖ http://bit.ly/1PC664c

ជាទ្រឹស្ដី ប្រទេសកម្ពុជាមានក្របខណ្ឌច្បាប់ល្អប្រសើរគ្រប់គ្រាន់សម្រាប់ការការពារសិទ្ធិមនុស្ស ដោយរួមមានទាំងសិទ្ធិបច្ចេកវិទ្យាផងដែរ។ ផ្នែកនេះនឹងធ្វើការត្រួតពិនិត្យទៅលើទ្រឹស្ដីការពារសិទ្ធិមនុស្សដែលផ្ដល់ឱ្យប្រជាពលរដ្ឋកម្ពុជា ដែលកម្ពុជាបានផ្ដល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិយ៉ាងច្រើននិងថែមទាំងមានការជានានៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ផងដែរ។

## ***សិទ្ធិសេរីភាពខាងការបញ្ចេញមតិ***

សិទ្ធិសេរីភាពខាងគំនិត និងយោបល់ត្រូវបានចែងក្នុងមាត្រា ១៩ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស("ស.ប.ស.ម") ហើយត្រូវបានបញ្ជាក់ឡើងវិញក្នុងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលកម្ពុជាជាភាគីមួយនៃសេចក្ដីប្រកាសនេះ។ មាត្រានេះបានចែងថា៖

*"ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្ដី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្ដី តាមការជ្រើសរើសរបស់ខ្លួន"*[10]

ទាំង ស.ប.ស.ម និង ក.អ.ស.ព.ន ត្រូវបានព្រាងឡើងជាមួយនឹងទស្សនវិស័យក្នុងការរួមបញ្ចូល និងបើកផ្លូវដល់ការអភិវឌ្ឍបច្ចេកវិទ្យាដែលតាមរយៈនេះបុគ្គលអាចអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ ដោយសារតែមានការបញ្ជាក់យ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិមួយដែលបានចែងថា មនុស្សគ្រប់រូបមានសិទ្ធិក្នុងការសំដែងមតិរបស់ខ្លួនតាមរយៈ *ប្រព័ន្ធផ្សព្វផ្សាយណាមួយ*។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបញ្ជាក់ថាវិធីក្នុងការបញ្ចេញមតិរួមបញ្ចូលនូវគ្រប់ទម្រង់ទាំងអស់ នៃវិធីសាស្ត្រទំនាក់ទំនងទាំងបែបអេឡិចត្រូនិច និងតាមរយៈប្រព័ន្ធអ៊ីនធឺណិត[11] មានន័យថាក្របខណ្ឌនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិមានប្រសិទ្ធិភាពអនុវត្តដូចគ្នាលើបច្ចេកវិទ្យាទំនាក់ទំនងថ្មីៗនិងកំពុងអភិវឌ្ឍន៍ ដូចជាអ៊ីនធឺណិត និងបណ្ដាញសង្គមជាដើម។

កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអនុម័តដោយឯកច្ឆ័នលើសេចក្ដីសម្រេចដំបូងបង្អស់ក្នុងការការពារសិទ្ធិមនុស្សលើបណ្ដាញអ៊ីនធឺណិត។ [12] សេចក្ដីសម្រេចដំបូងនេះត្រូវបានគាំទ្រដោយរដ្ឋជាសមាជិក និងរដ្ឋមិនមែនជាសមាជិករបស់គណៈកម្មាធិការសិទ្ធិមនុស្ស ជាង ៧០ ប្រទេស ដែលរួមមានចិន បារាំង សហរដ្ឋអាមេរិក និងអូស្ត្រាលីផងដែរ។ សេចក្ដីសម្រេចនេះបញ្ជាក់ថា

---

[10] ក.អ.ស.ព.ន មាត្រា ១៩.២។

[11] "គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប *វិចារណកថទូទៅលេខ៣៤៖ សេរីភាពនៃគំនិត និងការបញ្ចេញមតិ* CCPR/ C/GC/34 (GC 34)" (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) [១២]. អាចរកបានតាមរយៈ ៖ http://bit.ly/1xmySgV

[12] "ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់មហាសន្និបាត អ.ស.ប" *ការលើកកម្ពស់ ការការពារ និងការទទួលបានសិទ្ធិមនុស្សលើអ៊ីនធឺណិត* សេចក្ដីសម្រេច 20/8, A/HRC/RES/20/8" (ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១២) អាចរកបានតាមរយៈ ៖ http://bit.ly/1PSQrQ3

*"សិទ្ធិដែលមនុស្សទទួលបានការការពារនៅក្រៅបណ្ដាញអ៊ីនធឺណិត ត្រូវតែទទួលបានការការពារលើបណ្ដាញអ៊ីនធឺណិតដូចគ្នាដែរ"* ហើយត្រូវបានចាត់ទុកថាជាជំហានដ៏ជោគជ័យដំបូងក្នុងការគាំទ្រសិទ្ធិមនុស្សលើបណ្ដាញអ៊ីនធឺណិត ។ សេចក្ដីសម្រេចនេះទទួលស្គាល់បន្ថែមទៀតថា *"សកលលោក និងការបើកទូលាយលើបណ្ដាញអ៊ីនធឺណិតជាកត្តាជម្រុញមួយក្នុងការបង្កើនវឌ្ឍនភាពឆ្ពោះទៅកាន់ការអភិវឌ្ឍ"* ហើយធ្វើការអំពាវនាវដល់រដ្ឋដទៃទៀតក្នុងការ *"លើកកម្ពស់ និងសម្រួលដល់លទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត"។ សំខាន់ជាងនេះទៅទៀត សេចក្ដីសម្រេចនេះក៏ទទួលស្គាល់ផងដែរថា "អ៊ីនធឺណិតអាចជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍ និងការអនុវត្តសិទ្ធិមនុស្ស"។*[13]

យ៉ាងណាមិញ សិទ្ធិសេរីភាពខាងការបញ្ចេញមតិមិនមានលក្ខណៈជាច់ខាតនៅលើអ៊ីនធឺណិត ឬកន្លែងផ្សេងទៀតនោះទេ គឺខុសគ្នាពី ស.ប.ស មាត្រា ១៩ នៃ ក.អ.ស.ព.ន កម្រិតពីដែនកំណត់នៃសេរីភាពខាងគំនិតនិងការបញ្ចេញមតិក្រោមកាលៈទេសៈជាក់លាក់ណាមួយ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានចែងថាទម្រង់ជាក់លាក់ផ្សេងៗនៃការបញ្ចេញមតិគឺអាចមានការរឹតត្បិត ប៉ុន្តែការឹតត្បិតណាមួយត្រូវតែបំពេញតាមលក្ខខណ្ឌដែលបានចែងក្នុងមាត្រា ១៩(៣) ។[14] ដូចនេះ ការការពារសេរីភាពខាងការបញ្ចេញមតិមិនត្រូវលើសពីលក្ខខណ្ឌដែលចាំបាច់នោះទេ*"ដើម្បីការគោរពសិទ្ធិ ឬកិត្តិយសរបស់អ្នកដទៃ"* និងដើម្បី *ការពារសន្តិសុខជាតិ ឬសណ្ដាប់ធ្នាប់សាធារណៈ ឬ សុខភាព និងសីលធម៌សាធារណៈ។*[15]

ដូចនេះ រាល់បទប្បញ្ញត្តិណាមួយដែលប៉ះពាល់ដល់ការកម្រិតសេរីភាពខាងការបញ្ចេញមតិត្រូវតែបំពេញតាមលក្ខន្តិកៈដូចជា (១) ត្រូវបានកំណត់ដោយច្បាប់ (២) ត្រូវបានអនុវត្តក្នុងគោលបំណងការពារសិទ្ធិ ឬកិត្តិយសរបស់អ្នកដទៃ ឬដើម្បីការពារសន្តិសុខជាតិ និង(៣) មានការចាំបាច់ក្នុងការសម្រេចបាននូវគោលបំណងដែលបានរៀបរាប់ខាងលើ។[16] យោងទៅលើ គណៈកម្មាធិការសិទ្ធិមនុស្ស ទម្រង់នៃការបញ្ចេញមតិបែបនេះដែលអាចជាកម្មវត្ថុនៃការរឹតត្បិតស្របច្បាប់តាមមាត្រា ១៩(៣) រួមមាន (ប៉ុន្តែមិនកំណត់ចំពោះ) ពាក្យសំដីដែលមានលក្ខណៈស្អប់ ការបរិហារកេរ្តិ៍ ការបញ្ចេញមតិដែលនាំឲ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនាដែលចាត់ទុកថាជាការញុះញង់ ឲ្យមានការរើសអើង មានកំហឹង ឬអំពើហិង្សា។[17]

ជាងនេះទៅទៀត វិសាលភាពពិតប្រាកដនៃសិទ្ធិទាំងនេះត្រូវបានកំណត់ដោយប្រទេសនីមួយៗ ហើយអាចខុសៗគ្នារវាងជាតិនីមួយៗ ដែលអាចធ្វើឲ្យរដ្ឋមួយចំនួនបកស្រាយបញ្ញត្តិដើម្បីគាំទ្រដល់ការដាក់ពិរុទ្ធខ្លួន

---

[13] ដូចខាងលើ

[14] ឡា រុយ (F. La Rue) *"របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្ដីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពខាងគំនិត និងការបញ្ចេញមតិ"* A/HRC/17/27 (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១) [23]-[24]។ អាចរកបានតាមរយៈ ៖ http://bit.ly/QD35W5

[15] ក.ស.ស.ព.ន មាត្រា ១៩.៣។

[16] ចេស៊ីកា បុម (Jessica Bauml) "វាជារឿងឆ្កួត អ៊ីនធឺណិតឆ្កួត ៖ សាកលភាវូបនីយកម្ម និងការប្រឈមលើការដាក់ពិរុទ្ធខ្លួនឯងលើសិទ្ធិបច្ចេកវិទ្យា" (២០១១) Federal Communications Law Journal, Vol ៦៣, p. ៧០៧។

[17] ឡា រុយ (La Rue) (2011), ខាងលើលេខ៨ [២៥]។

ឯងលើបណ្ដាញអ៊ីនធឺណិត។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*បានចេញ* នូវសេចក្ដីសម្រេចមួយកំណត់ពីកាលៈទេសៈបែបណាដែលហាមឃាត់រដ្ឋនីមួយៗក្នុងការដាក់កម្រិតទៅលើសិទ្ធិដែលត្រូវបានការពារតាមមាត្រា ១៩ ។ ហេតុដូច្នេះហើយ រដ្ឋាភិបាល *មិន* ត្រូវបានអនុញ្ញាតឱ្យមានការរឹតត្បិតទៅលើ ៖

*(ក)ការពិភាក្សាលើគោលនយោបាយរដ្ឋាភិបាល និងការជជែកដេញដោលនយោបាយ រាយការណ៍អំពីសិទ្ធិមនុស្ស សកម្មភាពរបស់រដ្ឋាភិបាល និងអំពើពុករលួយក្នុងជួររដ្ឋាភិបាល ចូលរួមក្នុងការធ្វើបាតុកម្មដោយសន្តិវិធី ឬសកម្មភាពនយោបាយដោយ រួមបញ្ចូលទាំងសន្តិភាពនិងប្រជាធិបតេយ្យ ឬការសំដែងគំនិតយោបល់ និងការជំទាស់ សាសនា ឬជំនឿ*

*(ខ)លំហូរព័ត៌មាននិងគំនិតដោយសេរី ដោយបញ្ចូលទាំងការអនុវត្ត ក៏ដូចជាការហាមឃាត់ ឬការបិទការបោះពុម្ពផ្សាយដោយមិនសមហេតុផល ឬប្រព័ន្ធផ្សព្វផ្សាយនានា និងការរំលោភបំពានរដ្ឋបាល និងការដាក់ពិរុទ្ធខ្លួនឯង*

*(គ)លទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាប្រាស័យទាក់ទងបែបទំនើបរួមមានវិទ្យុ ទូរទស្សន៍ និងអ៊ីនធឺណិត។*

*(ឃ)អ្នកសារព័ត៌មានក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ*[18]

មុនពេលមានសេចក្ដីសម្រេចឆ្នាំ ២០១២ អង្គការសហប្រជាជាតិ មិនបានដាក់ចេញនូវគោលជំហរជាក់លាក់ណាមួយស្ដីពីការការពារសេរីភាពលើបណ្ដាញអ៊ីនធឺណិតនោះទេ ហើយបានត្រឹមតែផ្ដល់យោបល់ថាលទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណិតគួរត្រូវបានពិចារណាថាជាសិទ្ធិមនុស្សមួយផងដែរ។[19] ទោះជាយ៉ាងណាក៏ដោយ សេចក្ដីសម្រេចនេះបានបញ្ជាក់ថាការសំដែងមតិលើបណ្ដាញអ៊ីនធឺណិតស្ថិតក្នុងបរិបទនៃសិទ្ធិសេរីភាពខាងគំនិត និងបញ្ចេញមតិដែលត្រូវបានដាក់បញ្ចូលក្នុងលិខិតូបករណ៍សិទ្ធិមនុស្សជាមូលដ្ឋានដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ន។

សិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវបានធានាផងដែរនៅក្នុងច្បាប់ជាតិរបស់កម្ពុជា។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបានប្បញ្ញត្តិយ៉ាងច្បាស់មួយដែលទទួលស្គាល់និងធានាថា "*ពលរដ្ឋខ្មែរត្រូវមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សារព័ត៌មាន ការបោះពុម្ពផ្សាយ និងការប្រមូលផ្តុំ។*" សិទ្ធិនេះត្រូវបានបញ្ជាក់បន្ថែមដោយមាត្រា ៣១ ដែលបានចែងថាកម្ពុជាទទួលស្គាល់ និងគោរព ស.ប.ស.ម។ បន្ថែមពីលើនេះទៀត ក.អ.ស.ព.ន មានសុពលភាពអនុវត្តដោយផ្ទាល់ក្នុងច្បាប់ជាតិរបស់កម្ពុជា ដូចដែលបានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចរបស់ក្រុម

---

[18] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស Res. 2003/42 "សិទ្ធិសេរីភាពខាងគំនិតយោបល់ និងការបញ្ចេញមតិ" អ.ស.ប Doc. E/CN.4/RES/2003/42 (ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣) អាចរកបានតាមរយៈ ៖ http://bit.ly/23HrqM3

[19] មាត្រា១៩នៃ ស.ប.ស.ម សំដៅទៅលើសិទ្ធិក្នុងការស្រាវជ្រាវ ទទួល និងផ្ដល់ព័ត៌មាន និងយោបល់តាមរយៈបណ្ដាញផ្សព្វផ្សាយដោយគ្មានព្រំដែនកំណត់។

ប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបានចែងថា *"កតិកាសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់"* គឺជាផ្នែកមួយនៃច្បាប់កម្ពុជាដោយស្វ័យប្រវត្តិ ។[20]

## សិទ្ធិឯកជនភាព

សិទ្ធិឯកជនភាពត្រូវបានទទួលស្គាល់ដោយគ្មានលក្ខខណ្ឌថាជាសិទ្ធិមនុស្សមូលដ្ឋាន ដែលត្រូវបានជានានៅក្នុងមាត្រា ១២ នៃ ស.ប.ស.ម និងមាត្រា ១៧ នៃ ក.អ.ស.ព.ន។ ដែលមាត្រា ១៧ នេះបានចែងថាៈ

*១. គ្មានជនណាម្នាក់ត្រូវទទួលការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។*

*២.ជនគ្រប់រូប មានសិទ្ធិឲ្យច្បាប់ការពារប្រឆាំងនឹងការការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។*

ក្នុងបរិបទនៃសិទ្ធិបច្ចេកវិទ្យា អត្ថន័យនៃ "ការឆ្លើយឆ្លង" រួមមានទិន្នន័យឯកជនដែលត្រូវបានរក្សាទុក បញ្ជូន និងទទួលតាមបណ្តាញអ៊ីនធឺណិត។ ការបកស្រាយ និងវិសាលភាពនៃសិទ្ធិឯកជនមានភាពច្របូកច្របល់ដោយការផ្លាស់ប្តូរយ៉ាងលឿននិងធំសម្បើមមួយទៅកាន់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មាន("ICT") ដែលកើតមានឡើងក្នុងអំឡុងពេលប៉ុន្មានសតវត្សថ្មីៗនេះ ដែលបច្ចេកវិទ្យាទាំងនេះបានជះឥទ្ធិពលដល់ទស្សនៈនៃព្រំដែនរវាងកន្លែងសារធារណៈ និងកន្លែងឯកជន។

មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាផ្តល់ឱ្យប្រជាពលរដ្ឋនូវ *"ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅដ្ឋាន និង អាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមទូរសារ តាមទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា"*។ ដោយសាររដ្ឋធម្មនុញ្ញត្រូវបានតាក់តែងឡើងនៅដើមទសសវត្សឆ្នាំ១៩៩០ ពុំមានដាក់បញ្ចូលសេចក្តីយោងលើបណ្តាញអ៊ីនធឺណិត ឬ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានត្រូវបានបញ្ចូលនៅក្នុងនោះទេ។

មានទិដ្ឋភាពខុសគ្នាចំនួនពីរទាក់ទងនឹងសិទ្ធិឯកជន ដែលត្រូវបានវិភាគដូចខាងក្រោម ជាពិសេសពាក់ព័ន្ធនឹងស្ថានភាពនៃសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា ៖ (ក) ឯកជនភាពនៃការទំនាក់ទំនង និង(ខ) កិត្តិយស។

## ឯកជនភាពនៃការឆ្លើយឆ្លង

ជាទំលាប់ពីមុនមក អត្ថន័យនៃ "ការឆ្លើយឆ្លង" ក្នុង ស.ប.ស.ម និង ក.អ.ស.ព.ន ត្រូវបានបកស្រាយថាជាការទាក់ទងបែបលាយលក្ខណ៍អក្សរ តែយ៉ាងណាក្តី ពាក្យនេះបច្ចុប្បន្នត្រូវបានអនុវត្តគ្រប់ទម្រង់នៃទំនាក់ទំនង មិនកំណត់ហើយរួមបញ្ចូលទាំងអ៊ីនធឺណិតផងដែរ។ សិទ្ធិឯកជនរួមបញ្ចូលទាំងកាតព្វកិច្ចរបស់រដ្ឋក្នុងការទប់ស្កាត់ការជ្រៀតជ្រែកហួសហេតុលើការឆ្លើយឆ្លងរបស់បុគ្គល ទោះបីជាការជ្រៀតជ្រែកមួយចំនួនអាចត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈមួយចំនួនដែលបានកំណត់ ដូចជាការរក្សានូវសន្តិសុខជាតិជាដើម។

[20] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

អ្នករាយការណ៍ពិសេសបានកត់សម្គាល់នៅក្នុងរបាយការណ៍ឆ្នាំ២០១១ របស់ខ្លួនទៅលើ "ការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពខាងគំនិត និងបញ្ចេញមតិ" ថា *"ពុំមានច្បាប់ក្នុងការការពារទិន្នន័យប្រកបដោយប្រសិទ្ធិភាព ឬគ្រប់គ្រាន់ក្នុងរដ្ឋជាច្រើន"*។[21] យោងតាមអ្នករាយការណ៍ពិសេសបានលើកឡើងថា ការលេចឡើងនូវ*"និន្នាការគួរឲ្យព្រួយបារម្ភ"* ដែលរដ្ឋតម្រូវ ឬដាក់សម្ពាធទៅលើវិស័យឯកជនក្នុងការផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងអតិថិជនដូចជាទិន្នន័យទាក់ទងនឹងទីតាំងភូមិសាស្ត្រពីទូរស័ព្ទស្មាតហ្វូន និងមធ្យោបាយក្នុងការប្រើប្រាស់អ៊ីនធឺណិតផងដែរ។

### ***កិត្តិយស***

មាត្រា ១៧ នៃ ក.អ.ស.ព.ន កំណត់ថាសិទ្ធិឯកជនភាពពង្រីកវិសាលភាពទៅលើសិទ្ធិក្នុងការទទួលបានការការពារពីការជ្រៀតជ្រែកកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលណាម្នាក់ ហើយការរក្សានូវសិទ្ធិនេះធ្វើឲ្យមានការលេចឡើងនូវឧទាហរណ៍មួយ ដែលសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងមាត្រា ១៩ អាចត្រូវបានដាក់កំហិតដោយស្របច្បាប់។ លិខិតូបករណ៍សិទ្ធិមនុស្សមិនបានហាមឃាត់លើច្បាប់បរិហារកេរ្តិ៍នោះទេ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពុំមានការអនុវត្តដោយប្រុងប្រយ័ត្នទេ ច្បាប់ទាំងនោះអាចរំលោភបំពានដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

ជាតុផ្សំគន្លឹះនៃបទបរិហារកេរ្តិ៍គឺជាការអះអាងដោយមិនពិតចំពោះអង្គហេតុមួយ ដែលបង្កឲ្យមានការខូចខាតដល់កិត្តិយសរបស់បុគ្គលណាម្នាក់តាមរយៈការផ្សព្វផ្សាយទៅជនទីបី។ រដ្ឋភាគច្រើនបានអនុវត្តច្បាប់បរិហារកេរ្តិ៍ក្នុងគោលបំណងដើម្បីការពារនូវកិត្តិយសដល់បុគ្គលណាម្នាក់ ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តក្នុងរដ្ឋជាច្រើនជាការរំលោភបំពានលើច្បាប់បរិហារកេរ្តិ៍ ដោយប្រើប្រាស់ច្បាប់ទាំងនេះក្នុងការបន្ទុចបង្អាក់ការជជែកដេញដោលជាសារធារណៈ និងរារាំងការរិះគន់ស្របច្បាប់ទៅលើមន្ត្រី ឬបង្ហាញពីការប្រព្រឹត្តកំហុស ឬអំពើពុករលួយរបស់មន្ត្រីរដ្ឋាភិបាល។[22] ក្នុងវិធីសាស្ត្រដូចគ្នាដែរ ច្បាប់បរិហារកេរ្តិ៍ត្រូវបានយកមកប្រើជាលេសលើមូលដ្ឋានដែលថាការប្រើច្បាប់ទាំងនេះដើម្បីរក្សាសណ្តាប់ធ្នាប់សារធារណៈ ឬសន្តិសុខជាតិ។[23] តាមរយៈនិយមន័យនេះ ច្បាប់បរិហារកេរ្តិ៍ដាក់កម្រិតទៅលើសិទ្ធិមនុស្សមួយចំនួន ដូចជាសេរីភាពខាងការបញ្ចេញមតិ ដើម្បីជាប្រយោជន៍ដល់សិទ្ធិសំខាន់ផ្សេងទៀត ដូចជាការការពារកិត្តិយសជាដើម។ ពុំមានឋានានុក្រមជាស្វ័យប្រវត្តិរវាងសិទ្ធិទាំងនោះទេ ដូចនេះចាំបាច់ត្រូវមានការពិចារណាដោយប្រុងប្រយ័ត្នទៅតាមករណីជាក់ស្តែង ដើម្បីធានានូវតុល្យភាពមួយរវាងសិទ្ធិទាំងពីរនេះ។

### ***តុល្យភាពរវាងសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព***

---

[21] ឡា រុយ (La Rue) (២០១១) ដូចខាងលើលេខ៨ [៥៦]។

[22] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ , *វិចារណកថាទូទៅលេខ ៣៤, មាត្រា១៩, សេរីភាពនៃគំនិត និងការបញ្ចេញមតិ*, CCPR/C/GC/34, ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១១។ អាចរកបានតាមរយៈ ៖ http://bit.ly/1xmySgV.

[23] ឡា រុយ (La Rue) (2011), ដូចខាងលើលេខ១ [34]។

យោងទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ មានហេតុផលស្របច្បាប់មួយចំនួនក្នុងការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ រួមបញ្ចូលទាំងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការការពារសិទ្ធិ និងឯកជនភាពរបស់អ្នកដទៃ។ ករណីនេះទាក់ទងនឹងតុល្យភាពដ៏ផុយស្រួយមួយរវាងសិទ្ធិផ្សេងៗដែលពាក់ព័ន្ធគ្នា ប៉ុន្តែសេរីភាពខាងការបញ្ចេញមតិគួរតែត្រូវបានការពារជាពិសេសក្នុងបរិបទនយោបាយ។ ការរិះគន់មន្ត្រីរដ្ឋាភិបាលមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យអ្នកដែលអនុវត្តមុខងារសាធារណៈទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ ដូចនេះ ការការពារផ្លូវច្បាប់ទៅលើកិត្តិយស និងឯកជនភាពរបស់រូបវន្តបុគ្គលគឺមានលក្ខណៈទន់ខ្សោយជាងបុគ្គលសាធារណៈ។ សារៈសំខាន់ពិតប្រាកដនៃសេរីភាពខាងការបញ្ចេញមតិក្នុងវិស័យនយោបាយមានបញ្ជាក់យ៉ាងច្បាស់ក្នុងបទដ្ឋានច្បាប់អន្តរជាតិ។

គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិបានលើកឡើងពីសារៈសំខាន់នៃការអត់ឱនចំពោះការរិះគន់លើបុគ្គលសាធារណៈក្នុងសង្គមដែលមានសេរីភាព និងប្រកបដោយប្រជាធិបតេយ្យមួយ ៖

*"នៅក្នុងកាលៈទេសៈនៃការជជែកដេញដោលពាក់ព័ន្ធនឹងបុគ្គលសាធារណៈហើយនិងស្ថាប័នសាធារណៈនៅក្នុងវិស័យនយោបាយ កតិកាសញ្ញានេះបានឱ្យតម្លៃខ្ពស់ទៅលើការបញ្ចេញមតិយោបល់ ដូច្នេះ* ***អង្គហេតុដ៏តូចមួយដែលចាត់ទុកសេរីភាពខាងការបញ្ចេញមតិជាការប្រមាថដល់បុគ្គលសាធារណៈនោះមិនអាចបំពេញនូវលក្ខណ្ឌគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសព្រហ្មទណ្ឌបានទេ*** *ទោះបីជាបុគ្គលសាធារណៈអាចទទួលអត្ថប្រយោជន៍ពីកតិកាសញ្ញានេះក៏ដោយ។ ជាងនេះទៅទៀត បុគ្គលសាធារណៈរួមទាំងអ្នកមានសិទ្ធិអំណាចខ្ពស់ក្នុងវិស័យនយោបាយដូចជា ប្រមុខរដ្ឋ និងរដ្ឋាភិបាលគឺជាអ្នកដែលនឹងត្រូវទទួលរងការរិះគន់និងជំទាស់ក្នុងវិស័យនយោបាយ"*[24]

លើសពីនេះទៅទៀត អ្នករាយការណ៍ពិសេសបានផ្តល់យោបល់ថា"*ការដាក់ពន្ធធនាគារលើបុគ្គលណាម្នាក់ដើម្បីស្វែងរក ទទួលយក និងផ្សព្វផ្សាយព័ត៌មាន និងគំនិត កម្រនឹងមានហេតុផលថាជាវិធានការសមស្របក្នុងការសម្រេចបាននូវគោលបំណងស្របច្បាប់មួយតាមមាត្រា ១៩ កថាខណ្ឌទី៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយណាស់*"។[25] លើសពីនេះទៅទៀត អ្នករាយការណ៍ពិសេសក៏គាំទ្រឱ្យលុបចោលទោសព្រហ្មទណ្ឌលើបទបរិហារកេរ្តិ៍ ហើយអះអាងថា"*ការការពារសន្តិសុខជាតិ ឬការប្រឆាំងនឹងអំពើភេរវកម្ម មិនអាចត្រូវបានប្រើប្រាស់ក្នុងការបំពេញលក្ខខណ្ឌដើម្បីរឹតត្បិតលើសិទ្ធិខាងការបញ្ចេញមតិនោះទេ ប្រសិនបើរដ្ឋាភិបាលមិនអាចបញ្ជាក់ថា ៖ (ក) ការបញ្ចេញមតិមានគោលបំណងក្នុងការញុះញង់ឱ្យមាន*

[24] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *វិចារណកថាទូទៅលេខ ៣៤ មាត្រា ១៩ សេរីភាពនៃគំនិត និងការបញ្ចេញមតិ* CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១។ អាចរកបានតាមរយៈ ៖ http://bit.ly/1xmySgV

[25] ឡា រុយ (La Rue) (២០១១),ដូចខាងលើលេខ ៨ [៣៦]។

*អំពើហិង្សាភ្លាមៗ (ខ) ទំនងជាញុះញង់ឲ្យមានអំពើហិង្សា និង(គ)មានការផ្សារភ្ជាប់ដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិ និងអំពើហិង្សាដែលអាចកើតមាន។"*[26]

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានប្រកាន់ជំហរថាការប្រើប្រាស់យ៉ាងធ្ងន់ធ្ងរនូវបទបរិហារកេរ្តិ៍ក្នុងរឿងព្រហ្មទណ្ឌដើម្បីទប់ស្កាត់ការរិះគន់ទៅលើបុគ្គលសាធារណៈ និងតួអង្គនយោបាយគឺមិនបំពេញទៅតាមកាតព្វកិច្ចរបស់រដ្ឋក្នុងវិស័យសិទ្ធិមនុស្សឡើយ ៖

*"ច្បាប់បរិហារកេរ្តិ៍ត្រូវតែតាក់តែងឡើងដោយមានការយកចិត្តទុកដាក់ដើម្បីធានាថាច្បាប់ទាំងនោះ... មិនត្រូវបានយកមកអនុវត្តដើម្បីរាំងសេរីភាពខាងការបញ្ចេញមតិ។ ច្បាប់ទាំងនោះ ជាពិសេសច្បាប់បរិហារកេរ្តិ៍ក្នុងរឿងព្រហ្មទណ្ឌគួរតែដាក់បញ្ចូលនូវខចែងដែលគាំទ្រដល់ការពិត ហើយមិនគួរយកមកអនុវត្តក្នុងទម្រង់នៃការបញ្ចេញមតិយោបល់ដែលមិនមែនជាលក្ខខណ្ឌដើម្បីដាក់ទោសទណ្ឌឡើយ។ យ៉ាងហោចណាស់មតិយោបល់លើកឡើងអំពីបុគ្គលសាធារណៈ ត្រូវរួចផុតពីការដាក់ទោសព្រហ្មទណ្ឌ ឬក៏ឱ្យធ្វើការបកស្រាយ កែតម្រូវនូវពាក្យសម្តីមិនពិតដែលបានចេញផ្សាយទៅហើយនោះ ដោយពុំមានការព្យាបាទ។"*[27]

ដូចនេះ សិទ្ធិសេរីភាពខាងការបញ្ចេញមតិរួមបញ្ចូលនូវសិទ្ធិខាងការបញ្ចេញទស្សនៈ និងគំនិតដែលរងការបំពាន ការភ្ញាក់ផ្អើល ឬការរំខាន។ លើសពីនេះទៅទៀត គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ដោយគ្មានលក្ខខណ្ឌថាការរឹតត្បិតមិនគួរត្រូវបានអនុវត្តចំពោះការពិភាក្សាលើគោលនយោបាយរបស់រដ្ឋាភិបាល និងការជជែកដេញដោលនយោបាយ រាយការណ៍ពីបញ្ហាសិទ្ធិមនុស្ស រាយការណ៍ពីសកម្មភាពរដ្ឋាភិបាល និងអំពើពុករលួយក្នុងជួររដ្ឋាភិបាល ការចូលរួមក្នុងយុទ្ធនាការបោះឆ្នោត បាតុកម្មដោយសន្តិវិធីឬសកម្មភាពនយោបាយដោយរួមបញ្ចូលផងដែរនូវសកម្មភាពដើម្បីសន្តិភាព និងប្រជាធិបតេយ្យ និងការបញ្ចេញគំនិត និងការជំទាស់ សាសនា ឬជំនឿព្រមទាំងការបញ្ចេញមតិយោបល់របស់បុគ្គលនៅក្នុងក្រុមជនជាតិដើមភាគតិច ឬក្រុមដែលងាយរងគ្រោះ។[28]

ជាថ្មីម្តងទៀតសិទ្ធិឯកជនភាពអាចត្រូវបានដាក់កម្រិតតែក្នុងករណីលើកលែងមួយចំនួនប៉ុណ្ណោះ ដូចជាវិធានការត្រួតពិនិត្យតាមដានរបស់រដ្ឋ ដែលចាំបាច់សម្រាប់ការគ្រប់គ្រងសមស្របដើម្បីធានានូវយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ការបង្ការឧក្រិដ្ឋកម្ម ឬប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម។ ដូច្នេះសិទ្ធិសេរីភាពខាងការបញ្ចេញមតិអាចត្រូវបានអនុញ្ញាតប្រសិនបើលក្ខន្តិកៈក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវបានបំពេញតែប៉ុណ្ណោះ។ ដូចនេះត្រូវតែមានច្បាប់ជាតិច្បាស់លាស់ដែលកំណត់ពីកាលៈទេសៈមួយចំនួន ដែលសិទ្ធិឯកជនភាពរបស់រូបវន្តបុគ្គលត្រូវបានរឹតត្បិត។ វិធានការរឹតត្បិតសិទ្ធិនេះគួរត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋានដែលមានការសម្រេចចិត្ត

---

[26] ដូចខាងលើ

[27] សូមពិនិត្យលើ ៖ វិចារណកថាទូទៅ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លេខ៣៤ ខាងលើលេខ ២២

[28] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សេរីភាពនៃគំនិត និងការបញ្ចេញមតិ៖ *សេចក្តីសម្រេចអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស"* A/HRC/RES/12/16 ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ [៥]។ អាចរកបានតាមរយៈ ៖ http://bit.ly/1TAL9Z8

ដាក់លាក់មួយដោយអាជ្ញាធររដ្ឋដែលមានអំណាចស្របច្បាប់។ ជាចុងក្រោយ សកម្មភាពនេះត្រូវតែស្ថិតក្នុងគោលបំណងការពារសិទ្ធិអ្នកដទៃ និងត្រូវគោរពគោលការណ៍សមាមាត្រ។[29]

## ២.២ ក្របខណ្ឌច្បាប់ថ្នាក់តំបន់

កាលពីខែវិច្ឆិកា ឆ្នាំ២០១២ រដ្ឋជាសមាជិកទាំង១០នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ "អាស៊ាន" ដែលរួមមានប្រទេសកម្ពុជា បានអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ផ្តល់ជូនដល់បុគ្គលគ្រប់រូបនូវ *"សិទ្ធិសេរីភាពក្នុងការគិត និងសំដែងមតិ"* តាមមាត្រា ២៣ ដោយរួមមានសិទ្ធិក្នុងការ *"ប្រកាន់នូវគំនិតដោយគ្មានការជ្រៀតជ្រែក ជាលាយលក្ខណ៍អក្សរឬតាមរយៈមធ្យោបាយផ្សេងៗ"* សិទ្ធិឯកជនត្រូវបានចែងក្នុងមាត្រា ២១ ហើយសិទ្ធិនេះស្រដៀងគ្នាស្ទើរតែទាំងស្រុងជាមួយនឹងបញ្ញត្តិដែលបានកំណត់នៅក្នុង ស.ប.ស.ម ដែលកំណត់នូវការការពារពីការជ្រៀតជ្រែកតាមអំពើចិត្តទាក់ទងនឹង *"ការឆ្លើយឆ្លងនិងទិន្នន័យរបស់បុគ្គល"*។

សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន មានកថាខណ្ឌស្តីពីការដាក់កម្រិតជាទូទៅមួយក្នុងមាត្រា ៨ នៃគោលការណ៍បើកចំហរបស់ខ្លួនដែលផលប៉ះពាល់ចុងក្រោយគឺមិនសូវទទួលស្គាល់ ឬឱ្យតម្លៃទាបទៅលើសិទ្ធិមនុស្ស នៅក្រោមទំនៀមទំលាប់អន្តរជាតិ និង ក.អ.ស.ព.ន។ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន បានកំណត់ថាការរឹតត្បិតលើសេរីភាពជាមូលដ្ឋានអាចអាស្រ័យទៅលើកត្តាមួយចំនួនដូចជា *"ទាក់ទងនឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ សីលធម៌សាធារណៈ ព្រមទាំងសុខាមាលភាពទូទៅរបស់ប្រជាជនក្នុងសង្គមប្រជាធិបតេយ្យ"*។ ការកំណត់បែបនេះជាបញ្ហាមួយដោយសារតែវិសាលភាពនៃវិស័យចម្បងៗខកខានក្នុងការទទួលស្គាល់ថាសិទ្ធិមនុស្សមួយចំនួនក្នុងកាលៈទេសៈណាមួយក៏ដោយមិនអាចត្រូវបានដាក់កម្រិតដោយរដ្ឋនោះទេ។ ការកំណត់ទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលត្រូវបានការពារដោយ ក.អ.ស.ព.ន អាចធ្វើទៅបានអនុលោមទៅតាម ក.អ.ស.ព.ន តែប៉ុណ្ណោះ ហើយសិទ្ធិខ្លះមិនអាចធ្វើការរឹតត្បិតបាននោះទេ។ [30] ក្នុងបរិបទនេះ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ពុំស៊ីសង្វាក់ជាមួយនឹងកាតព្វកិច្ចជាអន្តរជាតិរបស់រដ្ឋជាសមាជិកអាស៊ានទាំងអស់នោះទេ។

## ២.៣ ក្របខណ្ឌច្បាប់ជាតិ

ទោះបីជាមានក្របខណ្ឌច្បាប់ក្នុងការការពារសិទ្ធិមនុស្សយ៉ាងណាក្តី ការអនុវត្តជាក់ស្តែង សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាត្រូវបានរំលោភបំពានជាប្រចាំ ហើយសិទ្ធិរបស់ជនរងគ្រោះនៅក្នុងប្រព័ន្ធតុលាការក៏ត្រូវបានរំលោភបំពានដោយសារអំពើពុករលួយ និងភាពមិនប្រក្រតីកើតឡើង។ មន្ត្រីតុលាការជាទូទៅមិនអើពើចំពោះការធានាសិទ្ធិមនុស្ស ខណៈដែលក្រុមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ត្រូវបាន

---

[29] ឡា រុយ (La Rue) (២០១១), ខាងលើលេខ ៨, [៥៩]

[30] ក.អ.ស.ព.ន មាត្រា ៤(២) មិនអនុញ្ញាតឱ្យធ្វើបដិបញ្ញតិចំពោះមាត្រា. ៦, ៧, ៨ (១)(២), ១១, ១៥, ១៦ & ១៧

អនុវត្តដោយរំលោភបំពាន ជាឧបករណ៍ដែលប្រើប្រាស់ប្រឆាំងនឹងអ្នកជំទាស់នឹងផលប្រយោជន៍របស់រដ្ឋាភិបាល ទាំងលើបណ្តាញអ៊ីនធឺណិត និងក្រៅបណ្តាញអ៊ីនធឺណិត។

ជាដំបូងផ្នែកនេះនឹងត្រួតពិនិត្យទៅលើច្បាប់ដែលមានស្រាប់ដែលជាញឹកញាប់ត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នកប្រើប្រាស់អ៊ីនធឺណិត និងអ្នកផ្សេងទៀតដែលសំដែងមតិជំទាស់ដូចជាបទបរិហារកេរ្តិ៍ និងបទញុះញង់។ ទីពីរ ផ្នែកនេះវិភាគទៅលើសេចក្តីស្នើច្បាប់ចំនួនពីរដែលគំរាមកំហែងដល់សិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា។

## *ក្រមព្រហ្មទណ្ឌ*

ខណៈពេលដែលសេរីភាពខាងការបញ្ចេញមតិត្រូវបានធានានៅក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ មានប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងក្រមព្រហ្មទណ្ឌដែលជាជំហរក្នុងការប្រឆាំងស្ទើរតែដោយផ្ទាល់ទៅលើសេរីភាពនេះ។ ចាប់តាំងពីច្បាប់នេះត្រូវបានអនុម័តក្នុងឆ្នាំ ២០១០ ក្រមព្រហ្មទណ្ឌដែលបានធ្វើបច្ចុប្បន្នភាពនេះត្រូវបានរិះគន់ពីសំណាក់អង្គការសិទ្ធិមនុស្សជាច្រើនដោយសារហេតុផលផ្សេងៗ រួមមានទាំងការដាក់កម្រិតយ៉ាងធ្ងន់ធ្ងរទៅលើសេរីភាពខាងការបញ្ចេញមតិ។[31] គួរកត់សម្គាល់ថា រដ្ឋមន្ត្រីក្រសួងព័ត៌មានលោក ខៀវ កាញ់ារិទ្ធិ បានលើកឡើងដោយសំដៅលើក្រមព្រហ្មទណ្ឌថា"ពីមុន ដោយប្រើប្រាស់ហេតុផលនៃ សេរីភាពនៃការបញ្ចេញមតិ និងស្ថានភាពគណៈបក្សជំទាស់ មនុស្សមួយចំនួនអាចជេរប្រមាថអ្នកណាមួយ ឬស្ថានប័នណាមួយក៏បាន។ ប៉ុន្តែបច្ចុប្បន្ននេះមិនអាចធ្វើដូច្នេះបានទៀតនោះទេ។"[32]

ជំពូក ២ នៃក្រមព្រហ្មទណ្ឌបានរៀបរាប់ពីប្បញ្ញត្តិ និងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ និងការជេរប្រមាថដែលផ្ទុយនឹងការអំពាវនាវម្តងហើយម្តងទៀតនៅលើឆាកអន្តរជាតិក្នុងការមិនដាក់ទោសព្រហ្មទណ្ឌលើបទបរិហារកេរ្តិ៍។ មាត្រា ៣០៥ និង៣០៧ បង្ហាញពីនិយមន័យនៃបទបរិហារកេរ្តិ៍ជាសធារណៈ និងការជេរប្រមាថជាសាធារណៈ។ តាមរយៈមាត្រាទាំងពីរនេះ ការប្រព្រឹត្តបទបរិហារកេរ្តិ៍ ឬការជេរប្រមាថអាចត្រូវធ្វើឡើង *"តាមលិខិត ឬគំនូរទោះជាប្រភេទណាក៏ដោយ"* ហើយដែល *"ផ្សព្វផ្សាយនៅក្នុងចំណោមសាធារណៈជន ឬដាក់តាំងឲ្យដល់សាធារណៈជនមើល"*។ ឃ្លាចុងក្រោយនៃប្បញ្ញត្តិនេះបង្កប់ន័យថា បុគ្គលណាក៏ដោយអាចត្រូវបានកាត់ទោសដោយសារការសន្ទនាជាលក្ខណៈឯកជនហើយត្រូវបានបង្ហាញជាធារណៈដោយមិនមានការយល់ព្រមពីបុគ្គលនោះ។ អ្វីដែលគួរឲ្យព្រួយបារម្ភនោះគឺ ឃ្លានេះស៊ីសង្វាក់គ្នានឹងក្រមព្រហ្មទណ្ឌទាំងមូល។

---

[31] សូមពិនិត្យមើលជាទូទៅ៖ "មតិយោបល់លើសេចក្តីព្រាងក្រមព្រហ្មទណ្ឌ" របាយការណ៍ចេញដោយអង្គការ *មាត្រា ១៩*, (ខែកញ្ញា ឆ្នាំ ២០០៩) អាចរកបានតាមរយៈ ៖ http://bit.ly/1SJKzaZ; "កម្ពុជា ៖ ក្រមព្រហ្មទណ្ឌថ្មីកាត់ផ្តាត់មតិដោយសេរី" *អង្គការឃ្លាំមើលសិទ្ធិមនុស្ស* (ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០) អាចរកបានតាមរយៈ ៖ http://bit.ly/1VJfUty និង "កំណត់ត្រាសង្ខេប ៖ ការត្រួតពិនិត្យលើច្បាប់កម្ពុជាពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ និងសេចក្តីសង្ខេបនៃឧទាហរណ៍ពីករណីថ្មីៗនេះដើម្បីបង្ហាញតើថាច្បាប់ត្រូវបានប្រើប្រាស់ និងបំពានយ៉ាងដូចម្តេចដើម្បីគាបសង្កត់មតិប្រឆាំង" ម.ស.ម.ក (ខែតុលា ឆ្នាំ២០១២) អាចរកបានតាមរយៈ ៖ http://bit.ly/1KrIjUj

[32] ដូចខាងលើ

បទល្មើសក្នុងមាត្រា៤៩៥ “បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ” មិនតម្រូវថាទាល់តែបទល្មើសកើតឡើងពិតប្រាកដដែលជាលទ្ធផលនៃការញុះញង់នោះទេ គឺគ្រាន់តែសកម្មភាពដែលបង្កើត“*ភាពចលាចលក្នុងសង្គម*”តែប៉ុណ្ណោះ។ មាត្រា ៤៩៦ ស្តីពី “បទញុះញង់ឲ្យមានការរើសអើង” គឺដូចគ្នាផងដែរ។ មាត្រាទាំងពីរភ្ជាប់ជាមួយនូវស្ថានទម្ងន់ទោសលើការព្យួរ “សិទ្ធិពលរដ្ឋ” ដែលមិនបានបញ្ជាក់ “ជាក់លាក់” មួយចំនួន។ ភាពមិនច្បាស់លាស់នៃចំនុចនេះផ្តល់ឱកាសដល់ប្រព័ន្ធតុលាការ និងស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋភិបាលក្នុងការសម្រេចថាតើសិទ្ធិពលរដ្ឋណាមួយដែលខ្លួនអាចដកហូតបាន ដែលនេះអាចរួមបញ្ចូលនូវសិទ្ធិក្នុងការបោះឆ្នោតផងដែរ។ មាត្រា ៥០២ ដាក់ទោសព្រហ្មទណ្ឌលើការជេរប្រមាថ និងអនុវត្តទៅលើ“*ជាការប្រើប្រាស់វាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល*”។ ជាតុផ្សំនៃបទល្មើសនេះមិនច្បាស់លាស់ និងមានលក្ខណៈអត្តនោម័តយ៉ាងខ្លាំង ហើយដែលធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ សុពលភាពជាក់ស្តែងនៃបទប្បញ្ញត្តិនេះដើម្បីដាក់ទោសព្រហ្មទណ្ឌដល់សកម្មភាពទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់មន្រ្តីសាធារណៈ។

មាត្រា ៥២៣ ប៉ះទង្គិចស្ទើរតែដោយផ្ទាល់ជាមួយនឹងមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ដោយសារមាត្រានេះដាក់ទោសឧក្រិដ្ឋដល់ការរិះគន់ទៅលើសកម្មភាព ឬសេចក្តីសម្រេចរបស់តុលាការ។ ផលប៉ះពាល់ពីមាត្រានេះដាក់កម្រិតយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់សារធាណៈជនក្នុងការផ្តល់មតិអវិជ្ជមានលើសេចក្តីសម្រេចណាមួយរបស់រដ្ឋាភិបាល ដែលជាឧបសគ្គដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការចូលរួមដោយសេរីក្នុងការជជែកដេញដោល និងការពិភាក្សាអំពីនយោបាយ ដែលជាសសរស្តម្ភនៃសង្គមប្រជាធិបតេយ្យ។

## *សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យាដែលមិនបាំង*

កាលពីខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាលបានប្រកាសពីចេតនារបស់ខ្លួនក្នុងការអនុម័ត “ច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យា” ដំបូងបង្អស់របស់កម្ពុជាក្នុងគោលបំណងគ្រប់គ្រងនូវមតិនៅលើបណ្តាញអ៊ីនធឺណិត និងដើម្បីបង្ការ “ក្រុមមនុស្ស ឬជនអាក្រក់” ពីការផ្សព្វផ្សាយព័ត៌មានមិនពិត។[33] សង្គមស៊ីវិលបានព្យាយាមស្នើសុំនូវសេចក្តីព្រាងច្បាប់ជាផ្លូវការពីរដ្ឋាភិបាល ប៉ុន្តែមិនមានការឆ្លើយតបច្បាស់លាស់នោះទេ។ អ្វីដែលគួរឲ្យព្រួយបារម្ភនោះកាលពីចុងខែឧសភា ឆ្នាំ២០១៥ រដ្ឋមន្រ្តីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រកាសថាច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យាកំពុងស្ថិតក្រោមការពិចារណា ហើយច្បាប់នេះនឹងបញ្ចូលនូវការដាក់ពិន័យព្រហ្មទណ្ឌលើ “*អ្នកដែលមានចេតនាអាក្រក់*” ដែលធ្វើ “*រិះគន់រដ្ឋាភិបាល*”។[34] សេចក្តីព្រាងច្បាប់នេះត្រូវបានបែកធ្លាយកាលពីខែមេសា ឆ្នាំ២០១៤ ប៉ុន្តែរដ្ឋាភិបាលបានបដិសេធក្នុងការបញ្ចេញផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់ជាផ្លូវការ។ សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យាដែលចម្រូងចម្រាស់នេះមានប្បញ្ញត្តិមួយចំនួនអាចរឹតត្បិតយ៉ាងធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិលើ

---

[33] ប្រៃហ្គេត ឌី សឺតូ ( Bridget Di Certo ) និង កឹម យុទ្ធណា “មន្ត្រីរដ្ឋាភិបាល ៖ ច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាដើម្បីបង្ការជនអាក្រក់” សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ( ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ) អាចរកបានតាមរយៈ ៖ http://bit.ly/1sW3Mvb

[34] ម៉ិច ដារ៉ា “ច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាការពារកិត្តិយសរដ្ឋាភិបាល” សារព័ត៌មាន ខេមបូឌា ដេលី (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៥ ) អាចរកបានតាមរយៈ ៖ http://bit.ly/1PfcTgS

បណ្តាញអ៊ីនធឺណិត ហើយបង្កឲ្យមានការដាក់ពិរុទ្ធខ្លួនឯង ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត។ ម.ស.ម.ក បានលើកឡើងពីកង្វល់នេះនាពេលកន្លងមកពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីសេចក្តីព្រាងច្បាប់នេះទៅលើសេរីភាពខាងការបញ្ចេញមតិ។[35]

ក្តីបារម្ភជាពិសេសគឺទៅលើមាត្រា ២៨ ដែលហាមឃាត់ដល់ការផ្សព្វផ្សាយដោយឈរលើមូលដ្ឋានមិនច្បាស់លាស់មួយចំនួន ហើយកំណត់ពីទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ធ្ងន់ធ្ងរ។ ប្បញ្ញត្តិដែលគួរឱ្យបារម្ភមួយចំនួននោះគឺការហាមឃាត់មាតិកាដែលមានលក្ខណៈ *"បង្កឲ្យមានអសន្តិសុខ អស្ថេរភាព និងភាពមិនស្រុះស្រួលនយោបាយ"* (មាត្រា២៨(៣)) ឬ *"ធ្វើឲ្យប៉ះពាល់ដល់សីលធម៌ និងវប្បធម៌ដ៏ល្អរបស់សង្គមជាតិ"* ដោយរួមបញ្ចូលទាំង *"ការបោកប្រាស់ ការបរិហារកេរ្តិ៍ និងការមួលបង្កាច់"* (មាត្រា ២៨(៥)(គ))។ មាត្រា ២៨(៤) ហាមឃាត់ខ្លឹមសារ "ធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ភ្នាក់ងាររដ្ឋាភិបាលណាមួយ" អាចជាឧបសគ្គដល់លទ្ធភាពរបស់សង្គមស៊ីវិលក្នុងការឃ្លាំមើលសកម្មភាពរបស់រដ្ឋាភិបាល ដែលមានតួនាទីសំខាន់មួយក្នុងសង្គមប្រជាធិបតេយ្យដែលកំពុងតែលេចឡើង ព្រមទាំងប្រើប្រាស់ដើម្បីបំបិតសម្លេងសកម្មជន និងគណៈបក្សជំទាស់ ។ លើសពីនេះទៅទៀត មាត្រា ៣៥ រួមបញ្ចូលនូវ *"ការរំលាយ"* ដែលជាទណ្ឌកម្មបន្ថែមដល់នីតិបុគ្គល ដែលរួមមានអង្គការសង្គមស៊ីវិល ដែលបានប្រព្រឹត្តបទល្មើសក្នុងមាត្រា ២១ ដល់មាត្រា ៣២ ហើយដាក់កម្រិតដោយមិនសមស្របទៅលើសេរីភាពខាងការបញ្ចេញមតិ។ ជាចុងក្រោយ គឺការស្នើឲ្យមានការដាក់បញ្ចូលនូវសមាជិករដ្ឋាភិបាលដែលមានអំណាចខ្លាំងក្លាក្នុងជួររដ្ឋាភិបាលនៅក្នុងគណៈកម្មាធិការជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា ("គ.ប.ប") ដូចដែលបានបញ្ជាក់ក្នុងមាត្រា ៦ ដែលនឹងមិនអាចបង្កើតឱ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យមួយសម្រាប់ការប្រើប្រាស់អ៊ីនធឺណិតនោះទេ។

ឆ្លើយតបទៅនឹងការមិនពេញចិត្តចំពោះការចេញសេចក្តីព្រាងច្បាប់លើកទីមួយ សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាលើកទីពីរត្រូវបានបែកធ្លាយដល់សង្គមស៊ីវិលមួយចំនួនពីក្រសួងមហាផ្ទៃក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៥។ សេចក្តីព្រាងលើកទីពីរនេះ ច្បាស់ណាស់ជា *"សេចក្តីព្រាងដែលកំពុងតែតាក់តែង"*។ ជាក់ស្តែង មាត្រាមួយចំនួនត្រូវបានចម្លងទាំងស្រុងពីកតិកាសញ្ញាស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យារបស់ក្រុមប្រឹក្សាអឺរ៉ុប ហើយយ៉ាងហោចណាស់មានមួយមាត្រាគឺ មាត្រា ២៥ ដែលដាក់លេខខុសពីមាត្រាក្នុងសេចក្តីព្រាង ប៉ុន្តែយោងទៅលើមាត្រាដែលមានក្នុងសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យាលើកទីមួយវិញ ដែលនាំឲ្យកើតមានជាសំណួរពាក់ព័ន្ធនឹងភាពដែលអាចជឿទុកចិត្តបាននៃឯកសារនោះ។ បន្ថែមពីលើនេះទៀត របៀបនៃការបែកធ្លាយសេចក្តីព្រាងទាំងពីរដល់អង្គការមួយចំនួនដែលត្រូវបានជ្រើសរើស មិនអាចជំនួសឲ្យដំណើរការធ្វើច្បាប់ដោយបើកចំហ និងមានការពិគ្រោះយោបល់ដែលឆ្លើយតបនឹងក្តីបារម្ភរបស់សាធារណៈជនទូទៅ និងសង្គមស៊ីវិលពាក់ព័ន្ធនឹងបញ្ហាតម្លាភាពនោះឡើយ។ ទោះបីជាសេចក្តីព្រាងដែលបែកធ្លាយជាលើកទីពីរនេះបានលុបចោលនូវប្បញ្ញត្តិដែលមានបញ្ហាធ្ងន់ធ្ងរមួយចំនួននៅក្នុងសេចក្តីព្រាងដំបូងក៏ដោយ ដូចជាការបង្កើត គ.ប.ប ជា

---

[35] "ច្បាប់អ៊ីនធឺណិត៖ តើឧបករណ៍សម្រាប់ការពារ ឬរឹតបន្តឹងសេរីភាពបញ្ចេញមតិ?" ម.ស.ម.ក (ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាមរយៈ ៖ http://bit.ly/1Zfcqji

ដើម សេចក្ដីព្រាងច្បាប់នេះក៏មានប្បញ្ញត្តិថ្មីមួយចំនួនដែលគំរាមកំហែងផងដែរដល់សិទ្ធិបច្ចេកវិទ្យា។ មាត្រា ២៧ អនុញ្ញាតឲ្យមានការរំលាយនីតិបុគ្គល ដោយរួមមានទាំងសង្គមស៊ីវិល ដោយឈរលើមូលដ្ឋាននៃ *"ឧក្រិដ្ឋកម្មបច្ចេកវិទ្យា"* ប្រព្រឹត្តដោយបុគ្គលដែលជាប់ពាក់ព័ន្ធនឹងអង្គការឬស្ថាប័នណានោះ។ ជាងនេះទៅទៀត សេចក្ដីព្រាងនេះផ្ដល់អំណាចទូលំទូលាយដល់នគរបាល និងអ្នកស៊ើបអង្កេតក្នុងការស្រាវជ្រាវ និងរឹបអូសទ្រព្យសម្បត្តិជនសង្ស័យនៃ *"ឧក្រិដ្ឋកម្មបច្ចេកវិទ្យា"* និងកង្វះខាតនូវការត្រួតពិនិត្យដោយតុលាការ និងនីតិវិធីការពារ ដែលជាការគំរាមកំហែងដល់សិទ្ធិឯកជនភាព និងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ បទឧក្រិដ្ឋដែលបង្កដោយរូបវន្តបុគ្គលដែលមានរៀបរាប់នៅក្នុងសេចក្ដីព្រាងនេះបានផ្ដល់និយមន័យយ៉ាងទូលំទូលាយ ព្រមទាំងផ្ដល់នូវវិសាលភាពជាចម្បងដល់រដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ដោយរំលោភបំពានប្រឆាំងនឹងអ្នកដែលខ្លួនចាត់ទុកថាជាអ្នកជំទាស់នឹងខ្លួន ដោយរំលោភបំពានលើសិទ្ធិមនុស្សដែលធានានៅថ្នាក់ជាតិ និងអន្តរជាតិ។ ឧទាហរណ៍មាត្រា ១៣(១) ដាក់ទោសព្រហ្មទណ្ឌលើការទទួលយកទិន្នន័យដែល *"ចាត់ទុកថាជាការសម្ងាត់ និងស្ថិតក្រោមកិច្ចការពារយ៉ាងពិសេសទៅនឹងការលួចភ្ជាប់"*។ ពុំមានចែងពីជាតុផ្សំដោយចេតនានោះទេ។ បុគ្គលម្នាក់មួយអាចត្រូវបានដាក់ពន្ធនាគារដោយសារទទួលបានសារអេឡិចត្រូនិចមួយដែលមានទិន្នន័យដូចខាងលើ បើទោះបីជាសារអេឡិចត្រូនិចនោះត្រូវបានផ្ញើរដោយភ័ន្តច្រឡំ ឬអ្នកទទួលមិនបានដឹងថាគាត់គ្មានសិទ្ធិមើលសារអេឡិចត្រូនិចនោះក៏ដោយ។ ចុងបញ្ចប់បទឧក្រិដ្ឋភាគច្រើនដែលបានរៀបរាប់ក្នុងសេចក្ដីព្រាងលើកទីពីរមានភាពជាន់គ្នា ហើយអាចត្រូវបានដាក់ទណ្ឌកម្មក្រមព្រហ្មទណ្ឌរួចទៅហើយ ដែលនេះអាច មានជាសំណួរថាតើចាំបាច់មានច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យានេះដែរឬទេ។

## ច្បាប់ថ្មីស្ដីពីទូរគមនាគមន៍

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋសភាបានអនុម័តជាផ្លូវការនូវសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីទូរគមនាគមន៍ ដែលក្រោយមកត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខានៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមរដ្ឋាភិបាល ច្បាប់នេះ *"បង្កើតឡើងក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់ដល់ភាគីទាំងអស់ដែលពាក់ព័ន្ធ រួមមាន(១) ប្រតិបត្តិករទូរគមនាគមន៍....(២)អ្នកប្រើប្រាស់រួមមានរូបវន្តបុគ្គល ស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន និង(៣)រដ្ឋាភិបាល..."*[36]

ច្បាប់ទូរគមនាគមន៍បង្កើនការគ្រប់គ្រងរបស់រដ្ឋាភិបាលលើវិស័យនេះ ហើយគំរាមកំហែងធ្ងន់ធ្ងរដល់ឯកជនភាពនៃការឆ្លើយឆ្លង និងសេរីភាពខាងការបញ្ចេញមតិ។ តាមមាត្រា ៦ និង ៧ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងមានអំណាចក្នុងការបញ្ជាដល់អ្នកផ្ដល់សេវាទូរគមនាគមន៍ក្នុងការប្រគល់ជូននូវទិន្នន័យ ប្រព័ន្ធ និងសម្ភារៈបរិក្ខារ ឬផ្ទេរការគ្រប់គ្រងប្រព័ន្ធទូរគមនាគមន៍ដល់ក្រសួងដើម្បីបម្រើដល់ផលប្រយោជន៍សន្តិសុខ ស្ថេរភាពជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ។ មាត្រា ៩៧ ដាក់ទោសព្រហ្មទណ្ឌលើការលួចស្ដាប់

[36] "សេចក្ដីប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៖ រដ្ឋសភាបានអនុម័តសេចក្ដីព្រាងច្បាប់ទូរគមនាគមន៍" អាចរកបានតាមរយៈ ៖ http://bit.ly/1PTxahA

ដល់បុគ្គលឯកជន ប៉ុន្តែធ្វើការលើកលែងលើការលួចស្ដាប់ *"ដោយមានការអនុញ្ញាតដោយអាជ្ញាធរស្របច្បាប់"* ដែលមានប្រសិទ្ធិភាពផ្ដល់ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នូវការអនុញ្ញាតក្នុងការធ្វើដោយសេរីក្នុងការតាមដានលើការឆ្លើយឆ្លងរបស់ពលរដ្ឋ ពីព្រោះមិនមានការការពារផ្លូវច្បាប់ ឬដោយនីតិវិធីត្រូវបានបញ្ចូលនៅក្នុងច្បាប់នេះនោះទេ ហើយក៏មិនមានការកំណត់ពីនីតិវិធីក្នុងការផ្ដល់ការយល់ព្រមផងដែរ។ មាត្រា ៩៣ ដល់មាត្រា ៩៦ មានបប្បញ្ញត្តិដែលមានពាក្យពេចន៍មិនច្បាស់លាស់ដែលអនុញ្ញាតការដាក់ពន្ធនាគារដោយធ្ងន់ធ្ងរ និងមិនសមាមាត្រដល់បុគ្គលដែលត្រូវបានរកឃើញថាកំពុងប្រើប្រាស់ទូរគមនាគមន៍ក្នុងការរៀបចំគម្រោងឧក្រិដ្ឋកម្ម ឬបំផ្លាញទ្រព្យសម្បត្តិ។ ទណ្ឌកម្មដូចដែលបានចែងក្នុងជំពូកទី១៤ ចាប់ពី ២.៤០០ដុល្លារ ដល់ចំនួនច្រើនរហូតដល់ ២៥០.០០០ ដុល្លារ និងជាប់ពន្ធនាគារចន្លោះពីមួយសប្ដាហ៍ដល់១៥ឆ្នាំ។

បន្ថែមលើក្ដីបារម្ភដែលបានលើកឡើងខាងលើ កង្វះខាតទាំងស្រុងនៃការប្រឹក្សាយោបល់ និងតម្លាភាពក្នុងដំណើរការអនុម័តច្បាប់ស្ដីពីទូរគមនាគមន៍យ៉ាងតក់ក្រហល់បែបនេះ គឺផ្ទុយនឹងសិទ្ធិទទួលបានព័ត៌មាន និងគោលការណ៍អភិបាលកិច្ចក្នុងលិទ្ធិប្រជាធិបតេយ្យ។

### ***បទប្បញ្ញត្តិថ្មីស្ដីពីទិន្នន័យទូរស័ព្ទ***

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនាយកដ្ឋាននគរបាលជាតិបានប្រកាសរួមគ្នាថានៅត្រឹមថ្ងៃទី២៣ ខែកញ្ញា បទប្បញ្ញត្តិនឹងត្រូវបានចាប់បង្ខំអនុវត្ត ដែលតាមរយៈនេះអ្នកផ្គត់ផ្គង់សេវាកម្មទូរស័ព្ទចល័តមានកាតព្វកិច្ចក្នុងការផ្ដល់ជូនដល់នគរបាលនូវព័ត៌មានអត្តសញ្ញាណពិស្ដាររបស់អ្នកកាន់កាប់ស៊ីមទូរស័ព្ទទាំងអស់ក្នុងប្រទេសកម្ពុជា។[37] លោក ឆៃ ស៊ីណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ បានអះអាងថា *"៧០ ភាគរយនៃជនក្រៅសង្គម"* ប្រើប្រាស់ស៊ីមទូរស័ព្ទដែលមិនបានចុះបញ្ជីក្នុងគោលបំណងប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ដូចនេះជាការចាំបាច់ក្នុងការអនុវត្តបទប្បញ្ញត្តិថ្មី។ [38] អ្នកលក់ស៊ីមទូរស័ព្ទរាយដែលមិនអនុវត្តតាមបទប្បញ្ញត្តិនេះនឹងត្រូវទទួលទោសព្រហ្មទណ្ឌ។ គិតមកដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ នេះមិនមានវិធានការណាមួយត្រូវបានអនុវត្តក្នុងការបង្ក្រាបលើស៊ីមទូរស័ព្ទដែលមិនបានចុះបញ្ជីទាំងនោះទេ។[39]

## ៣. កម្ពុជា ៖ សិទ្ធិបច្ចេកវិទ្យាក្នុងការអនុវត្តជាក់ស្ដែង

ផ្នែកនេះធ្វើការពិចារណាទៅលើស្ថានភាពនៃសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយធ្វើការជ្រើសរើសករណីរំលោភបំពានសិទ្ធិបច្ចេកវិទ្យាចំនួន ១០ ផ្សេងៗគ្នា ហើយនឹងវិភាគដោយសង្ខេបនូវករណីនីមួយៗក្នុងបរិបទសង្គម និងច្បាប់ឱ្យបានទូលំទូលាយ។ ផ្នែកនេះនឹងធ្វើការគូសបញ្ជាក់បន្ថែមពីការគំរាម

---

[37] វង្ស សុខហេង និង ចេមី អេលឡូត (Jamie Elliot) "ការទប់ស្កាត់ស៊ីមកាត" សារព័ត៌មាន*ភ្នំពេញប៉ុស្ដិ៍* (ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1KoPtZo

[38] ឃី សុវុឌ្ឍី និង ថូយឡឺ អូខានែល (Taylor O'Connell) "ទោះបីជាមានការគំរាម ស៊ីមដែលមិនបានចុះបញ្ជីនៅអាចដំណើរការ" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1SrCV6M

[39] ដូចខាងលើ

កំហែងមួយចំនួនដោយមន្ត្រីសាធារណៈទៅលើអ្នកដែលរិះគន់រដ្ឋាភិបាលនៅលើបណ្តាញអ៊ីនធឺណិត ដែលគំរាមកំហែងក្នុងការបង្កើតនូវវប្បធម៌ដាក់ពិរុទ្ធខ្លួនឯងក្នុងសកម្មភាពនយោបាយ។

ករណីផ្សេងៗគ្នាខាងក្រោមចាប់ពីមតិយោបល់ដែលមិនបង្កគ្រោះថ្នាក់ ដល់ការគំរាមសម្លាប់ពិតប្រាកដ ដោយគូសបញ្ជាក់ពីភាពស្មុគស្មាញនៃវិស័យច្បាប់ និងការទាមទារឲ្យមានវិចារណញ្ញាណនិងឯករាជ្យភាពនៃប្រព័ន្ធតុលាការនៅពេលបង្កើតតុល្យភាពរវាងសេរីភាពខាងការបញ្ចេញមតិនិងសិទ្ធិមួយចំនួន ដូចជាសិទ្ធិឯកជនភាពជាដើម។ ដូចដែលបានបញ្ជាក់ក្នុងផ្នែក ២.១ ខាងលើ តុល្យភាពនេះត្រូវធ្វើឡើងដោយឈរលើមូលដ្ឋានករណីជាក់ស្តែងនីមួយៗ ប៉ុន្តែការរិះគន់ទៅលើមន្ត្រីសាធារណៈ និងការអនុវត្តរបស់រដ្ឋាភិបាលគួរតែត្រូវបានផ្តល់ជូននូវការការពារជាពិសេសស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ លទ្ធផលនៃការសង្កេតការណ៍របស់ ម.ស.ម.ក បង្ហាញថា ចាប់តាំងពីខែសីហា ឆ្នាំ២០១៥ មក យ៉ាងហោចណាស់ប្រជាពលរដ្ឋចំនួន២៣ នាក់ ត្រូវបានគំរាមកំហែង ដោយសារការបញ្ចេញមតិរិះគន់លើបណ្តាញសង្គម។ បុគ្គលចំនួន ៧ នាក់បន្ថែមទៀតត្រូវបានចាប់ខ្លួនដោយសារការបញ្ចេញមតិយោបល់លើបណ្តាញអ៊ីនធឺណិតក្នុងអំឡុងពេលដូចគ្នានេះផងដែរ ហើយមកដល់បច្ចុប្បន្ននេះ បុគ្គលមួយរូបកំពុងស្ថិតក្នុងពន្ធនាគារនៅឡើយ។

### ***ការព្រមានដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន***

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ក្នុងពិធីប្រគល់សញ្ញាប័ត្រដល់និស្សិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងរាជធានីភ្នំពេញ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានថាអ្នកប្រើប្រាស់ហ្វេសប៊ុកដែលរិះគន់គោលនយោបាយរដ្ឋាភិបាលទាក់ទិននឹងបញ្ហារសើប ឬជេរប្រមាថបុគ្គលណាមួយអាចត្រូវបានតាមដានឃើញក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ លោកក៏បានលើកឡើងពីករណីកាត់ទោសនិស្សិតមហាវិទ្យាល័យ ឈ្មោះ គង់ រ៉ៃយ៉ា ផងដែរ (មានព័ត៌មានពិស្តារខាងក្រោម) ដោយបានលើកឡើងថា *"អ្នកធ្វើបដិវត្តពណ៌ត្រូវបានចាប់ខ្លួនភ្លាមៗ"*។ [40] ក្រៅពីកង្វល់ផ្នែកសិទ្ធិមនុស្សជុំវិញការចាប់ខ្លួនពលរដ្ឋជាបន្តបន្ទាប់ដូចដែលបានបញ្ជាក់ខាងក្រោម មតិយោបល់ដែលបានលើកឡើងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនមែនជាសញ្ញាណល្អប្រសើរសម្រាប់អនាគតនៃសេរីភាពខាងការបញ្ចេញមតិក្នុងប្រទេសកម្ពុជានោះទេ ហើយអាចបង្កើតឲ្យមានវប្បធម៌ភ័យខ្លាច និងការដាក់ពិរុទ្ធខ្លួនឯង ក្នុងចំណោមប្រជាពលរដ្ឋដែលប្រើប្រាស់អ៊ីនធឺណិត។ ការព្រមានទាំងនេះភាគច្រើនមានទិសដៅទៅលើ គ.ស.ជ ដែលធ្វើឲ្យលោក កឹម សុខា អនុប្រធានគណបក្ស គ.ស.ជ ណែនាំដល់សមាជិកជាយុវជនរបស់បក្សឲ្យមានការប្រុងប្រយ័ត្នជាមួយនឹងការប្រើប្រាស់បណ្តាញសង្គម និងមតិលើបណ្តាញសង្គមរបស់ខ្លួន។ លោកបានបញ្ជាក់ថា ៖ *"យើងមិនគួរណាលេងល្បែងដែលគេដាក់អន្ទាក់មកលើយើងនោះទេ...ជាពិសេសលើហ្វេសប៊ុក "* ។[41] កាលពីពេលថ្មីៗនេះ លោកនាយករដ្ឋមន្ត្រីបាន

---

[40] ពេជ សុធារី "ហ៊ុន សែនព្រមានអ្នកប្រើហ្វេសប៊ុកថាគាត់កំពុងតាមដាន" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1PuX6OC

[41] ម៉ិច ដារ៉ា និង អាឡិច វីលៀមនីម (Alex Willemyns) "សុខា ព្រមានយុវជនកុំឱ្យប្រើប្រាស់ហ្វេសប៊ុកដោយមានលក្ខណៈញុះញង់" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/20mhB1m

លើកឡើងវិញនូវមតិយោបល់របស់លោកកាលពីពេលមុនថា អ្នកដែលជេរប្រមាថលោកលើទំព័រហ្វេសប៊ុក អាចត្រូវបានតាមដានរកឃើញក្នុងរយៈពេលតែប៉ុន្មានម៉ោងតែប៉ុណ្ណោះ។[42] នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ថ្មីៗនេះ ជាការឆ្លើយតបនឹងសលាកប័ត្រព័ត៌មានស្តីពីសិទ្ធិបច្ចេកវិទ្យាដែលបានចេញផ្សាយដោយ ម.ស.ម.ក អ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន បានថ្លែងថារដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការចាប់ខ្លួនប្រជាពលរដ្ឋ ប្រសិនបើ "*មិនគោរព*" នាយករដ្ឋមន្ត្រី ហ៊ុន សែន។[43] ផលប៉ះពាល់នៃការព្រមាននេះនឹងកើតមាន ជាពិសេស នៅពេលមានការព្រមានពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែមិនទាន់មានរូបរាងច្បាស់លាស់នៅឡើយ។ ទោះជាយ៉ាងណា ការព្រមានទាំងនេះពិតជានាំទៅរកការបង្កើតនូវវប្បធម៌ដាក់ពិរុទ្ធភាពខ្លួនឯង ក្នុងចំណោមសហគមន៍អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជាដែលធ្វើឲ្យផលប៉ះពាល់ដោយប្រយោលលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

*ករណីទី១ ៖ គង់ រ៉ៃយ៉ា និង "បដិវត្តន៍ពណ៌"*

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៥ និស្សិតវ័យ ២៥ ឆ្នាំម្នាក់ ឈ្មោះ គង់ រ៉ៃយ៉ា បានបង្ហោះមតិយោបល់លើទំព័រហ្វេសប៊ុករបស់ខ្លួនថា "*តើមានអ្នកណាចង់ធ្វើបដិវត្តពណ៌ជាមួយខ្ញុំដែរឬទេ? ថ្ងៃណាមួយ នាពេលឆាប់ៗនេះ ខ្ញុំនឹងធ្វើបដិវត្តពណ៌ក្នុងគោលបំណងផ្លាស់ប្តូររបបផ្តាច់ការ។ ទោះបីជាខ្ញុំត្រូវជាប់គុក ឬស្លាប់ក៏ដោយ ខ្ញុំត្រូវតែធ្វើ*"។ នៅថ្ងៃទី២១ ខែសីហា លោកត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ មុនពេលត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃស។ ការចោទប្រកាន់នេះធ្វើឡើងតាមមាត្រា ៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងពាក្យសម្តីដែលប្រកាសក្នុងទីសាធារណៈ ឬ ការញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ។ រ៉ៃយ៉ា ត្រូវបានសាកសួរបន្ថែមនៅថ្ងៃទី១០ ខែកញ្ញា និងថ្ងៃទី១៥ ខែកញ្ញា ដោយការសាកសួរទាំងពីរលើកនេះមិនមានអ្វីដែលជាបទល្មើសចំពោះការបង្ហោះមតិយោបល់នៅលើទំព័រហ្វេសប៊ុកនោះទេ។ សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការនៅថ្ងៃទី២៥ ខែកុម្ភៈ ហើយនឹងប្រកាសសាលក្រមនៅថ្ងៃទី១៥ ខែមីនា។ ក្នុងអំឡុងពេលសវនាការ រ៉ៃយ៉ា បានប្រាប់តុលាការថាពេលនេះខ្លួនមានការសោកស្តាយចំពោះ "កំហុស" តែទោះជាយ៉ាងណា ព្រះរាជអជ្ញាបដិសេធថា មតិយោបល់គាត់បាន "*បង្កឲ្យមានចលាចលធ្ងន់ធ្ងរដល់សន្តិសុខសង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ*"[44] មកដល់ពេលនេះគាត់ត្រូវបន្តឃុំខ្លួននៅឡើយ ហើយប្រឈមនឹងការជាប់ពន្ធនាគាររយៈពេលបីឆ្នាំប្រសិនបើរកឃើញថាមានទោស។

ការចាប់ខ្លួននេះធ្វើឡើងក្នុងគោលបំណងកំណត់មុខសញ្ញាទៅលើប្រជាពលរដ្ឋដែលធ្វើការសំដែងមតិជំទាស់នៅលើបណ្តាញអ៊ីនធឺណិតក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ។ ប៉ុន្តែ មិនដូចទៅនឹងជនសង្ស័យដទៃនោះ

---

[42] វង្ស សុខេង "ការកែរូបថតគ្រួសារធ្វើឲ្យនាយករដ្ឋមន្ត្រីមិនសប្បាយចិត្ត" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី ១ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1nF6uEf

[43] ពេជ្រ សុធារី "សង្គមស៊ីវិលកត់សម្គាល់ថារដ្ឋាភិបាលបង្កើនការគំរាមកំហែងអ្នកបង្ហោះសារនៅលើបណ្តាញអ៊ីនធឺណិត" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦). អាចរកបានតាមរយៈ ៖ //bit.ly/1UtgTA5

[44] ប៊ុត គឹមសាយ "និស្សិតម្នាក់ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការបង្ហោះអំពីបដិវត្តពណ៌នៅលើហ្វេសប៊ុក" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦)អាចរកបានតាមរយៈ៖ http://bit.ly/1pnnNLI

ទេ ដូចជាសមាជិកព្រឹទ្ធសភាគណបក្សប្រឆាំងលោក ហុង សុខហួរ គង់ រ៉ៃយ៉ា ដែលមិនបានដឹកនាំគណបក្សនយោបាយណាមួយ ឬមិនមានឥទ្ធិពលនយោបាយខ្លាំងក្លាផងនោះ។ គ្រាន់តែជានិស្សិតសាកលវិទ្យាល័យច្បាស់ណាស់ គង់ រ៉ៃយ៉ា មិនមានមធ្យោបាយដឹកនាំប្រជាពលរដ្ឋកម្ពុជាធ្វើបដិវត្តនោះទេ។ ការបង្ហោះមតិយោ បល់របស់ គង់ រ៉ៃយ៉ា គឺគ្រាន់តែជាការសំដែងឡើងពីការមិនពេញចិត្តនឹងរដ្ឋាភិបាល ដែលនេះមិនមែនជាបទឧក្រិដ្ឋនោះទេ។ ម្តាយរបស់ គង់ រ៉ៃយ៉ា លោកស្រី ហ៊ិន សុផាត ក៏បានបញ្ជាក់ផងដែរថាកូនរបស់អ្នកស្រីគឺ *"គ្រាន់តែជានិស្សិតសាកលវិទ្យាល័យឆ្នាំទីមួយប៉ុណ្ណោះ គាត់មិនមានមធ្យោបាយក្នុងការដឹកនាំបដិវត្តទេ គាត់គ្រាន់តែសំដែងនូវអារម្មណ៍ផ្ទាល់ខ្លួនពីអ្វីដែលគាត់ឃើញថាជាភាពមិនប្រក្រតីនៅក្នុងសង្គមតែប៉ុណ្ណោះ"*។

ឆ្លើយតបនឹងការចាប់ខ្លួនរបស់ គង់ រ៉ៃយ៉ា លោក សុខ ទូច អ្នកវិភាគដ៏លេចធ្លោមួយរូប ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យខេមរៈ បានលើកឡើងថា *"យុវជននៅសាកលវិទ្យាល័យនេះកំពុងតែត្រូវបានបំពុលដោយបញ្ហានយោបាយ"*។ លោកបានគូសបញ្ជាក់ពីការមិនយល់ស្របរបស់លោកលើសកម្មភាពនយោបាយក្នុងចំណោមសិស្សនិស្សិតថា *"សំដីរបស់គាត់ ឬ ការសំដែងមតិរបស់គាត់ត្រូវបានចាត់ទុកថាលើសពីសេរីភាពខាងការបញ្ចេញមតិដែលរដ្ឋាភិបាលធ្វើការពិចារណា"*។[45] ករណីដែលគួរឲ្យចាប់អារម្មណ៍នោះគឺករណីរបស់ លោក សុខ ទូច ដែលជាករណីសំខាន់មួយក្នុងចំណោមករណីលេចធ្លោមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិបច្ចេកវិទ្យា ដែលមានបញ្ជាក់ខាងក្រោម។

*<u>ករណីទី២ ៖ ការគំរាមសម្លាប់បណ្ឌិត សុខ ទូច</u>*

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៥ ពលករចំណាកស្រុកមួយរូបឈ្មោះ ផាង សីហា អាយុ ២៧ ឆ្នាំ ត្រូវបានចាប់ខ្លួនបន្ទាប់ពីបានបង្ហោះមតិយោបល់នៅលើទំព័រហ្វេសប៊ុករបស់ខ្លួនដែលមានគណនីយឈ្មោះ "Sey Hu" ថា*"កាំភ្លើងនេះទុកបាញ់ក្បាល សុខ ទូច បណ្ឌិតដែលមានខួរឆ្កែ បណ្ឌិតដែលបានប្តូរប្រវត្តិសាស្ត្រ បណ្ឌិតដែលបានលក់ខួររបស់គាត់ទៅឲ្យយួន"*។[46] រូបថតកាំភ្លើងខ្លីនឹងគ្រាប់ចំនួន ១០ គ្រាប់ត្រូវបានបង្ហោះជាមួយនឹងពាក្យពេចន៍ទាំងនេះ។ ទោះបីជាបណ្ឌិត សុខ ទូច ដែលត្រូវបានប្រគល់ភារកិច្ចក្នុងការស្រាវជ្រាវការងាររបស់រដ្ឋាភិបាលក្នុងការកំណត់ព្រំដែនរវាងកម្ពុជា នឹងវៀតណាម មិនបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏នគរបាលបានចុះមកសាកសួរលោក សីហា បន្ទាប់ពីមានព័ត៌មាននៃការគំរាមនេះបានសាយភាយលើបណ្តាញសង្គម។ ក្រោយមកលោក សីហា បានសារភាពថាបានបង្ហោះមតិយោបល់គំរាមសម្លាប់ ហើយត្រូវសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ពីបទ *"គំរាមសម្លាប់"* តាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។ នៅក្នុងលិខិតមួយច្បាប់ចុះនៅថ្ងៃទី ១៧ ខែតុលា លោកបានសុំអភ័យទោសចំពោះលោក សុខ ទូច និងសុំការអត់អោន ដែលតាមរយៈនេះ

---

[45] ប៊ុត គឹមសាយ "និស្សិតម្នាក់ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការបង្ហោះអំពីបដិវត្តពណ៌នៅលើហ្វេសប៊ុក" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦)អាចរកបានតាមរយៈ៖ http://bit.ly/1pnnNLl

[46] អួន ភាព "ប៉ូលីសស៊ើបអង្កេតការគំរាមសម្លាប់លើអ្នកស្រាវជ្រាវព្រំដែន" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1QbbKGS និង Xinhua "ប៉ូលីសកម្ពុជាចាប់ខ្លួនបុរសដែលគម្រាមសម្លាប់អ្នកស្រាវជ្រាវព្រំដែនលើបណ្តាញហ្វេសប៊ុក" សារព័ត៌មាន *ខ្មែរថាម* (ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1TU8R2W

លោកទូច បានឆ្លើយតបថាលោកមិនបានចោទប្រកាន់ សីហា ឡើយ ហើយករណីនេះគួរតែពាក់ព័ន្ធនឹងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការផ្តន្ទាទោស ផាង សីហា ឱ្យជាប់ពន្ធនាគាររយៈពេល១៨ ខែ ប៉ុន្តែត្រូវបានព្យួរទោសរយៈពេល១២ ខែ។[47] ករណីបែបនេះពាក់ព័ន្ធនឹងការគំរាមសម្លាប់ ហើយច្បាស់ណាស់គួរតែត្រូវបានញែកឲ្យដាច់គ្នាពីករណីដែលបានបង្ហោះមតិយោបល់ដែលមិនបង្កគ្រោះថ្នាក់នៅលើបណ្តាញអ៊ីនធឺណិត។ ភាពខុសគ្នានេះតម្រូវឲ្យមានសុភវិនិច្ឆ័យពីសំណាក់តុលាការកម្ពុជា ដោយ ថ្លឹងថ្លែងអំពីសិទ្ធិ និងផលប្រយោជន៍ ហើយលើកយកអង្គហេតុទាំងអស់នៃករណីទាំងនោះទៅពិចារណា។

*<u>ករណីទី៣ ៖ បណ្ឌិត សុខ ទូច បានគំរាមនិស្សិត</u>*

ក្នុងហេតុការណ៍ដាច់ដោយឡែកពីគ្នាមួយទៀតគឺ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ លោក សុខ ទូច បានគំរាមដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ជួសមុខឲ្យសាកលវិទ្យាល័យខេមរៈលើអតីតនិស្សិតមួយរូបដែលបានសរសេរបង្ហោះលើទំព័រហ្វេសប៊ុក ដោយរិះគន់លើថ្លៃចំណាយផ្សេងៗដែលតម្រូវដោយសាកលវិទ្យាល័យ។ [48] ការគំរាមនេះបានស្ងប់ស្ងាត់ទៅវិញ បន្ទាប់ពីនិស្សិតស្រីរូបនោះបានធ្វើការសូមអភ័យទោសជាសាធារណៈ នឹងបានលុបមតិយោបល់របស់នាងចេញ។ ការប្រើប្រាស់បទល្មើសព្រហ្មទណ្ឌលើការបរិហារកេរ្តិ៍ដើម្បីបង្ក្រាបទៅលើការរិះគន់ស្របច្បាប់ដែលអាច "*ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះសាកលវិទ្យាល័យ*" ដូចដែលលោក សុខ ទូច បានអះអាង កំពុងតែជាបញ្ហាយ៉ាងធ្ងន់ធ្ងរ។ មតិយោបល់នេះមិនបង្កគ្រោះថ្នាក់អ្វីឡើយ ហើយស្ថិតក្នុងព្រំដែននៃការបញ្ចេញមតិស្របច្បាប់។ ការគំរាមកំហែង និងការលុបចោលមតិយោបល់នាពេលក្រោយនេះអាចបង្កើតបាននូវយុទ្ធសាស្ត្រដ៏គ្រោះថ្នាក់មួយសម្រាប់សាកលវិទ្យាល័យ ដែលជាទីប្រជុំនៃការបញ្ចេញមតិផ្នែកនយោបាយ ក្លាយជាកន្លែងបំបិទការសំដែងមតិរបស់អ្នកមាននិន្នាការនយោបាយជំទាស់។ គ្រោះថ្នាក់នេះកាន់តែធ្ងន់ធ្ងរឡើង ដោយថ្មីៗមានសារាចរពីក្រសួងអប់រំ យុវជន និងកីឡាហាមប្រាមសកម្មភាពនយោបាយ និងតម្រូវឲ្យមានការអនុញ្ញាតពីក្រសួងជាមុនចំពោះសកម្មភាពផ្សេងៗទៀត ដែលមិនពាក់ព័ន្ធនឹងនយោបាយនៅតាមសាកលវិទ្យាល័យ និងសាលារៀន។[49]

*<u>ករណីទី៤ ៖ និស្សិតម្នាក់ត្រូវបានកាត់ទោសពីបទ "គំរាមបំផ្ទុះគ្រាប់បែក"</u>*

តៅ សារឿន អាយុ២៦ ឆ្នាំនិងជាអតីតនិស្សិតសាកលវិទ្យាល័យត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ បន្ទាប់ពីបានផ្សព្វផ្សាយលើទំព័រហ្វេសប៊ុកដែលត្រូវបានចាត់ទុកថាជាការគំរាមសម្លាប់រដ្ឋមន្ត្រី

---

[47] អួន ភាព "ការគំរាមកំហែងនៅលើហ្វេសប៊ុកបណ្តាលឱ្យបុរសម្នាក់ជាប់ពន្ធនាគារ៦ខែ" សារព័ត៌មាន *ខេមបូឌា ដេលី* (២៥ កុម្ភៈ ឆ្នាំ ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1S7Is13

[48] ឃី សុវុឌ្ឍី និង អាតូនី ចេនសិន (Anthony Jensen) "បណ្ឌិតល្បីឈ្មោះគំរាមប្តឹងនិស្សិត" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1UNGcKW

[49] ម៉ិច ដារ៉ា "ក្រសួងព្រមានដាក់ទោសទៅលើសកម្មភាពនយោបាយនៅសាលារៀន" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១២ ខែ សីហា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1UtgYng

ក្រសួងមហាផ្ទៃគឺ លោក ស ខេង។ និស្សិតរូបនោះត្រូវបានចោទប្រកាន់ពីបទ *"គំរាមសម្លាប់"* តាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ។ ដោយខឹងសម្បារនឹងការផ្លាស់ប្តូរម្តងហើយម្តងទៀតនូវកាលបរិច្ឆេទនៃពិធីចែកសញ្ញាប័ត្រដែលមានលោក ស ខេង ចូលរួមថ្លែងសុន្ទរកថាផងនោះ តៅ សារឿន បានប្រើប្រាស់ទំព័រហ្វេសប៊ុកដើម្បីបញ្ចេញកំហឹងរបស់ខ្លួនដោយនិយាយថានឹងបំផ្ទុះគ្រាប់បែកនៅក្នុងកម្មវិធីនេះ។ គាត់ប្រឈមនឹងការជាប់ពន្ធនាគាររយៈពេលពីរឆ្នាំចំពោះការចោទប្រកាន់ទាំងនេះ។ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៥ សារឿន បានសរសេរលិខិតមួយច្បាប់ជូនឧបនាយករដ្ឋមន្ត្រី ស ខេង ដើម្បីស្នើសុំការអត់ឱនទោសដោយអះអាងថាគាត់មិនមានបំណងគំរាមកំហែងនោះទេ ប៉ុន្តែគ្រាន់តែមិនសប្បាយចិត្តនឹងការប្តូរកាលបរិច្ឆេទតែប៉ុណ្ណោះ។ បន្ទាប់ពីឧបនាយករដ្ឋមន្ត្រីបានឆ្លើយតប ដោយអភ័យទោសដល់ សារឿន ចំពោះការគំរាមកំហែងនេះ ក្រោយមកតុលាការបានសម្រេចដោយធ្វើការពិចារណាលើកត្តាទាំងនេះដោយបានបន្ធូរបន្ថយទោសរបស់ សារឿន មកត្រឹមរយៈពេល១៥ ខែ ដែលគាត់បានអនុវត្តទោសរយៈពេលត្រឹមតែមួយខែប៉ុណ្ណោះ។ ការចោទប្រកាន់ភ្លាមៗដោយតុលាការនេះបញ្ជាក់ពីឥទ្ធិពលដែលត្រូវបានអនុវត្តជារឿយៗដោយរដ្ឋាភិបាលទៅលើតុលាការកម្ពុជា។ ម្យ៉ាងទៀត ការផ្លាស់ប្តូរនេះបញ្ជាក់ថាតុលាការទទួលស្គាល់ថា"ការគំរាមនោះ" មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការចោទប្រកាន់ផ្លូវច្បាប់តាំងពីដំបូង ដែលការចោទប្រកាន់នេះគួរតែត្រូវបានទំលាក់ចោលហើយលើកលែងទោសដល់ តៅ សារឿន។

*<u>ករណីទី៥ ៖ សមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ និងសន្ធិសញ្ញាព្រំដែនក្លែងក្លាយ</u>*

កាលពីនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ សមាជិកព្រឹទ្ធសភាគណបក្សជំទាស់លោក ហុង សុខហួរ ត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំ និងញុះញង់ ហើយត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារព្រៃស ប៉ុន្មានថ្ងៃបន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឲ្យមានការចាប់ខ្លួនរូបលោកនៅក្នុងសុន្ទរកថាមួយដែលបានចោទប្រកាន់លោកពីបទ "ក្បត់ជាតិ" ដែលបានបង្ហោះនូវសន្ធិសញ្ញាព្រំដែនកម្ពុជា-វៀតណាមឆ្នាំ១៩៧៩ ក្លែងក្លាយ លើទំព័រហ្វេសប៊ុក របស់លោក សមរង្ស៊ី កាលពីថ្ងៃទី១២ ខែសីហា។ បន្ទាប់មកសមាជិកព្រឹទ្ធសភារូបនោះត្រូវបានចោទប្រកាន់ក្រោមមាត្រាចំនួនបីនៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលមានទោសជាប់ពន្ធនាគារយ៉ាងតិចរយៈពេល១៧ឆ្នាំ។ ក្រុមមេធាវីការពារក្តីរបស់គាត់ថ្លែងថា ការចោទប្រកាន់នោះផ្ទុយទាំងស្រុងទៅនឹងអភ័យឯកសិទ្ធិដែលបានផ្តល់ជូនសមាជិកព្រឹទ្ធសភាតាមរដ្ឋធម្មនុញ្ញកម្ពុជា ដែលការពារពួកគេឱ្យរួចផុតពីការចាប់ខ្លួន និងការឃុំខ្លួនលើកលែងតែក្នុងករណីដែលមានការយល់ព្រមពីព្រឹទ្ធសភាផ្ទាល់ ឬនៅពេលត្រូវបានចាប់ខ្លួនដោយផ្ទាល់ក្នុងអំឡុងពេលប្រព្រឹត្តបទល្មើសជាក់ស្តែង។

ក្រុមមេធាវីការពារក្តីសមាជិកព្រឹទ្ធសភា ហុង សុខហួរ អះអាងថាមិនមានភស្តុតាងដែលថាលោក សុខហួរ ដឹងពីភាពមិនត្រឹមត្រូវក្នុងឯកសារដែលបានបង្ហោះលើទំព័រហ្វេសប៊ុកនោះទេ ហើយបើទោះជាមិនត្រូវបានទទួលស្គាល់ជាឯកសារផ្លូវការក៏ដោយ ក៏ការប្រើសន្ធិសញ្ញាក្លែងក្លាយរបស់លោកពុំមែនជាបទល្មើសព្រហ្មទណ្ឌនោះឡើយ មានន័យថាអភ័យឯកសិទ្ធិសមាជិកសភារបស់លោកមិនអាចត្រូវបានប៉ះពាល់បានទេ។ ក្នុងករណី

នេះនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាត់ទុកថាជាទោសឧក្រិដ្ឋលើសេចក្តីថ្លែងការណ៍អំពីប្រវត្តិសាស្ត្រដែលមិនត្រឹមត្រូវ ដើម្បីជាមធ្យោបាយបង្ក្រាបបក្សជំទាស់ ដែលនេះបង្ហាញថាលោកមានអំណាចក្នុងការចាប់ខ្លួន និងដាក់គុកជនណាម្នាក់ នៅពេលណាក៏បាន។[50]

កាលពីថ្ងៃទី២៦ ខែកុម្ភៈ តុលាការកំពូលបានបើកសវនាការលើសំណើសុំនៅក្រៅឃុំរបស់លោក ហុង សុខហួរ។ ខណៈដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍បានបដិសេធសំណើសុំនៅក្រៅឃុំជាច្រើនដងរួចមក លោក សុខហួរ បានប្តឹងទៅតុលាការកំពូលដោយយោងទៅលើបញ្ហាសុខភាព និងសន្យាដាក់តម្កល់ប្រាក់ជានាចំនួន២០ លានរៀល (ប្រហែល ៥.០០០ដុល្លាអាមេរិក) និងលិខិតឆ្លងដែនសញ្ជាតិខ្មែរ និងបារាំងផងដែរ។ តុលាការកំពូលនឹងធ្វើការសម្រេចលើករណីនេះនៅថ្ងៃទី៤ ខែមិនា ឆ្នាំ២០១៦។[51]

ពាក់ព័ន្ធនឹងករណីនេះ ក៏មានការចេញដីកាចាប់ខ្លួនលោក សត្យា សម្បត្តិ និងលោក អ៊ឹង ជុងលាង ផងដែរ ដែលជាអ្នកគ្រប់គ្រងទំព័រហ្វេសប៊ុករបស់លោកសមរង្ស៊ី ដែលបានបង្ហោះសន្ធិសញ្ញា។ លោក សម្បត្តិ ត្រូវបានចោទប្រកាន់ពីបទសមគំនិតក្នុងការក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារក្លែងក្លាយ និងញុះញង់បង្កឲ្យមានភាពចលាចលក្នុងសង្គមធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តនៅថ្ងៃទី១២ និងទី១៣ ខែសីហា ឆ្នាំ២០១៥[52] ហើយលោក ហ៊ុន សែន បានអំពាវនាវដល់បុគ្គលទាំងពីរនេះឲ្យត្រឡប់ចូលខ្លួនមកសារភាពពីបទសមគំនិតនោះ[53]។

លើសពីនេះទៅទៀត មានការចោទប្រកាន់បន្ថែមពីបទសមគំនិតក្លែងបន្លំ និងញុះញង់ប្រឆាំងនឹងលោក សម រង្ស៊ី ប្រធាន គ.ស.ជ កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ក្រោយមកលោកខកខានមិនបានមកបង្ហាញខ្លួនក្នុងតុលាការដើម្បីសាកសួរពីការបង្ហោះវីដេអូដែលមានបញ្ចូលសន្ធិសញ្ញាព្រំដែនក្លែងក្លាយធ្វើឡើងដោយសមាជិកព្រឹទ្ធសភា ហុង សុខហួរ នោះឡើយ។[54] មន្ត្រីតុលាការចោទប្រកាន់លោក រង្ស៊ី ថាជាអ្នកសមគំនិតមួយរូបដោយសារការបង្ហោះសន្ធិសញ្ញានោះបានធ្វើឡើងនៅលើទំព័រហ្វេសប៊ុករបស់លោក ហើយបានតម្រូវឲ្យរូបលោកចូលបង្ហាញខ្លួននៅតុលាការដើម្បីសាកសួរពីវីដេអូនោះ។[55] លោក រង្ស៊ី កំពុងស្ថិតនៅក្នុងការនិរទេសខ្លួននៅឡើយដោយសារតែការយាយីពីប្រព័ន្ធតុលាការក្នុងរឿងស្រដៀងគ្នានេះ។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ

---

[50] តាំង វីដា "មេធាវីការពារក្តី លោក សុខហួរ ទាមទាររកភ័ស្តុតាង" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1JWYucq

[51] គុច ណារ៉េន "សមាជិកព្រឹទ្ធសភា គ.ប.ជ ស្នើសុំតុលាការកំពូលនៅក្រៅឃុំ" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1LUfjjs

[52] ម៉ិច ដារ៉ា "ដីកាចាប់ខ្លួនអ្នកគ្រប់គ្រងហ្វេសប៊ុករបស់លោក សម រង្ស៊ី" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1PTCv8r

[53] សូន តូទុន (Shaun Turton) និង វង្ស សុខេង "សមាជិក គ.ស.ជ បីរូបសុំសិទ្ធិជ្រកកោន" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1KD2AGw.

[54] ឃី សុវុឌ្ឍី និង អាឡិច វីល្លៀមនីម (Alex Willemyns) "ដីកាចាប់ខ្លួនមួយទៀតប្រឆាំងនឹងលោក សម រង្ស៊ី" សារព័ត៌មាន *ខេមបូឌា ដេលី* ( ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1WfM5RM

[55] ម៉ិច ដារ៉ា "មានការបញ្ជាឱ្យចាប់ខ្លួនអ្នកគ្រប់គ្រង ហ្វេសប៊ុករបស់ លោក រង្ស៊ី" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/207D1PD

២០១៥ សភាអឺរ៉ុបបានអនុម័តសេចក្តីសម្រេចមួយដោយអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា លុបចោលដីកាចាប់ខ្លួនលោក សម រង្ស៊ី។ ករណីនេះគេអាចដឹងយ៉ាងច្បាស់ពីបរិបទដែលរដ្ឋាភិបាលបង្ក្រាបទៅលើបក្សប្រឆាំង តែទោះជាយ៉ាងណាក៏ដោយករណីនេះបានបង្ហាញពីស្ថានភាពបញ្ចេញមតិផ្នែកនយោបាយតាមរយៈបច្ចេកវិទ្យាគឺជាក្តីបារម្ភពីស្ថានភាពសិទ្ធិមនុស្សផងដែរ ។

*ករណីទី៦ ៖ ការគំរាមកំហែងលើលោក ហ៊ុន សែន*

នៅក្នុងប្រសាសន៍របស់លោក ហ៊ុន សែន ដែលលើកឡើងថា អ្នកដែលបញ្ចេញមតិយោបល់ជេរប្រមាថលើបណ្តាញសង្គម អាចត្រូវបានរកឃើញក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ ក្នុងនោះដែរកសិករម្នាក់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ហើយត្រូវបានចោទប្រកាន់ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការចាប់ខ្លួន ដោយសារការគំរាមកំហែងដល់អាយុជីវិតរបស់នាយករដ្ឋមន្ត្រី។[56] មតិយោបល់ ដែលបានបង្ហោះលើបណ្តាញសង្គមមានឈ្មោះថា "Som Orn Koko" ដែលថា "*ថ្ងៃ៧មករា ជាថ្ងៃស្លាប់របស់អ្នក*"។ ការបង្ហោះនេះត្រូវបាន រកឃើញថានៅក្នុងខេត្តកំពង់ធំ ដែលមន្ត្រីនាយកដ្ឋានសន្តិសុខផ្ទៃក្នុងត្រូវបានបញ្ជូនឲ្យចុះស៊ើបអង្កេត ហើយកសិករឈ្មោះ ម៉ាន់ សំអ៊ាន់ និងបងប្អូនជីដូនមួយរបស់គាត់ ប៊ិន សុធា ត្រូវបានឃុំខ្លួន។ ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំបានចោទប្រកាន់តាមមាត្រា ២៣៣ និង៥០៣ នៃក្រមព្រហ្មទណ្ឌ ពីបទជេរប្រមាថ និងការគំរាមសម្លាប់ ដែលអាចប្រឈមនឹងការជាប់ពន្ធនាគារពីប្រាំមួយថ្ងៃ ដល់ពីរឆ្នាំ។ អ្នកជិតខាងរបស់ សំអ៊ាន់ បានជួយការពាររូបគាត់ ហើយបានចូលរួមសវនាការនៅតុលាការខេត្ត និងរៀបចំដង្ហែរក្បួនស្នើឱ្យលោក ហ៊ុន សែន ដោះលែងរូបគាត់ ជាមួយគ្នានេះដែរ ម្តាយរបស់គាត់បានលើកឡើងថា គណនីយហ្វេសប៊ុកកូនរបស់គាត់ត្រូវបានគ្រប់គ្រងដោយមនុស្សផ្សេងទៀត។[57] លោក សំអ៊ាន់ ត្រូវបានឃុំខ្លួនមុនពេលជំនុំជម្រះប្រមាណជាមួយខែ មុនពេលត្រូវបានដោះលែងឱ្យនៅក្រៅឃុំកាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។ បន្ទាប់ពីការដោះលែងមកគាត់បានលើកឡើងថា មានអ្នកផ្សេងប្រើប្រាស់គណនីយហ្វេសប៊ុករបស់គាត់ដើម្បីសរសេរមតិយោបល់ជេរប្រមាថនោះ។[58]

*ករណីទី៧ ៖ ពាក្យចចាមអារ៉ាមពីការស្លាប់របស់លោក ហ៊ុន សែន*

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ពាក្យចចាមអារ៉ាមពីការស្លាប់របស់លោក ហ៊ុន សែន បានចាប់ផ្តើមសាយភាយដោយផ្អែកលើការបង្ហោះតាមហ្វេសប៊ុកដោយមានទាំងរូបភាពបុរសម្នាក់គឺជាលោក ហ៊ុន សែន ដោយមានអក្សរនៅខាងក្រោមមានខ្លឹមសារថា "*ហ៊ុន សែន បានស្លាប់បន្ទាប់ពីត្រូវបណ្តាសាររបស់ប្រជាពលរដ្ឋ*

---

[56] យី សុវុឌ្ឍី "កសិករម្នាក់ត្រូវបានចោទប្រកាន់ដោយសារការគំរាមនាយករដ្ឋមន្ត្រីលើហ្វេសប៊ុក" សារព័ត៌មាន *ខេមបូឌា ដេលី* ( ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៦ ) អាចរកបានតាមរយៈ ៖ http://bit.ly/20Npt1n

[57] ម៉ៃ ទិត្យថារ៉ា "អ្នកភូមិអង្វរនាយករដ្ឋមន្ត្រីឲ្យលើកលែងទោសដល់អ្នកគម្រាមសម្លាប់លោក" សារព័ត៌មានខ្មែរថាម (ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ) អាចរកបានតាមរយៈ ៖ http://bit.ly/1nLDLyj

[58] ម៉ិច ដារ៉ា "បុរសម្នាក់ស្នើសុំនៅក្រៅឃុំបន្ទាប់ពីគម្រាមនាយករដ្ឋមន្ត្រី" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1U4N0FQ

*ខ្មែរក្នុងឆ្នាំ២០១៤។ សូមឲ្យគាត់ចុះនរកប្រាំពីរជាន់។ ទោះបីជាគាត់បានស្លាប់ក៏ដោយ ក៏គាត់ត្រូវវេទនាជារៀងរហូត"*[59] គណនីយដែលបានបង្ហោះនេះត្រូវបានចែករំលែកបន្តជាង ៤០០ ដង មានឈ្មោះថា "Kim Bopha"។ ឆ្លើយតបជាសាធារណៈទៅនឹងពាក្យចចាមអារាមនេះ លោក ហ៊ុន សែន បានបង្ហោះលើទំព័រផ្លូវការរបស់គាត់ ដោយចោទប្រកាន់ថា នេះត្រូវបានតាក់តែងដោយ *"គណបក្សមួយដែលបានដឹកនាំដោយមនុស្សអាក្រក់ និងអ្នកបោកប្រាស់អាជីព"* ដែល *"តែងតែរត់គេចខ្លួន"*។[60] ទីប្រឹក្សាលោក ហ៊ុន សែន គឺលោក អាណាន់ដា យ៉ាត បានគំរាមចាត់វិធានការផ្លូវច្បាប់លើការបង្ហោះនេះ ហើយការចាប់ខ្លួនមួយបានធ្វើឡើងនៅថ្ងៃទី២៥ ខែមករា។ ជនសង្ស័យត្រូវបានដោះលែងបន្ទាប់ពីមានការសន្និដ្ឋានថា *"ឈ្មោះរបស់គាត់ត្រូវបានអ្នកផ្សេងទៀតយកទៅប្រើប្រាស់"។*[61] ពុំមានភាពច្បាស់លាស់ណាមួយបញ្ជាក់ថា តើការសន្និដ្ឋាននេះធ្វើឡើងយ៉ាងដូចម្តេចនោះទេ។

*<u>ករណីទី៨ ៖ លោក ហ៊ុន ម៉ាណែត ដាក់ពាក្យបណ្ដឹងពីបទបរិហារកេរ្តិ៍</u>*

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ លោក ហ៊ុន ម៉ាណែត កូនប្រុសច្បងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានដាក់ពាក្យបណ្ដឹងបរិហារកេរ្តិ៍ទៅលើអ្នកប្រើប្រាស់ហ្វេសប៊ុកឈ្មោះ ឆាំ ចាន់នី ជាការឆ្លើយតបនឹងការផ្សាភ្ជាប់ លោក ម៉ាណែត និងម្ដាយរបស់គាត់គឺលោកជំទាវ ប៊ុន រ៉ានី ទៅនឹងការជួញដូរឈើខុសច្បាប់នៅក្នុងការបង្ហោះមួយមានខ្លឹមសារថា *"ឧក្រិដ្ឋជនព្រៃឈើកាច់កុងត្នា ព្រោះចង់កាន់កាប់តំបន់ព្រៃបានផលត្រកូល ហ៊ុន សែន"។*[62] នៅក្នុងការបង្ហោះនោះ ចន្នី បានអះអាងថាលោក ម៉ាណែត និងម្ដាយរបស់គាត់គឺលោកជំទាវ ប៊ុន រ៉ានី ផ្ដល់ការការពារដល់ឧកញ៉ា លឹម ប៊ុណ្ណា និងឧកញ៉ា សឹង សំអុល។ របាយការណ៍របស់ អង្គការគ្លូបិលវីតណេស ដែលមានចំណងជើងថា *"ដើមឈើគ្រួសារកម្ពុជា ៖ ការកាប់ឈើខុសច្បាប់ និងការលេបយកទ្រព្យសម្បត្តិសាធារណៈ"*[63] ដែលរដ្ឋាភិបាលបានតិះទៀន ទាំងតាមពាក្យសំដីខាងក្រៅ និងអេឡិចត្រូនិក ដោយបានភ្ជាប់គ្រួសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅនឹងជំនួញកាប់ឈើខុសច្បាប់ ដោយអះអាងថាគ្រួសារនេះបានផ្ដល់នូវអភ័យឯកសិទ្ធិពីទណ្ឌកម្មពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់របស់ពួកគេ។ គ្រួសារនេះបានបដិសេធដាច់ខាតចំពោះការចោទប្រកាន់ទាំងនេះ។

ការឆ្លើយតបរបស់លោក ហ៊ុន ម៉ាណែត ចំពោះការបង្ហោះនេះតាមរយៈហ្វេសប៊ុកផងដែរថា *"នៅក្នុងសង្គមប្រជាធិបតេយ្យមួយ ពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ប៉ុន្តែ ការអនុវត្តសេរីភាពខាង*

---

[59] មាស សុខជា "ពាក្យចចាមអារ៉ាម ពីការស្លាប់របស់នាយករដ្ឋមន្ត្រី បង្កឲ្យមានការខឹងសម្បារ" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1RZiBcd

[60] ម៉ិច ដារ៉ា "ជនសង្ស័យដែលបង្កពាក្យចចាមអារ៉ាមពីការស្លាប់របស់នាយករដ្ឋមន្ត្រីត្រូវបានចាប់ខ្លួន" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1P8ZKYS.

[61] ដូចខាងលើ

[62] គុច ណារ៉េន " លោក ហ៊ុន ម៉ាណែត ដាក់ពាក្យបណ្ដឹងចំពោះការបង្ហោះលើហ្វេសប៊ុក" សារព័ត៌មាន ខេមបូឌា ដេលី (ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1KoYRfC.

[63] គ្លូបិលវីតណេស (ខែមិថុនា ឆ្នាំ២០០៧), <http://bit.ly/1W0wlSt>,

*ការបញ្ចេញមតិត្រូវមានការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់បុគ្គល"*[64] មតិរបស់លោក ហ៊ុន ម៉ាណែត បង្ហាញពីដែនកំណត់ចំពោះការបញ្ចេញមតិដោយសេរី តែយ៉ាងណាមិញ បរិបទនៃមតិយោបល់របស់គាត់គ្រាន់តែជាការប្រាប់ប៉ុណ្ណោះ។ នៅក្នុងប្រទេសកម្ពុជា ដែលស្ថាប័នតុលាការត្រូវបានប្រើប្រាស់ជាទម្លាប់ដោយអ្នកនយោបាយជាន់ខ្ពស់ដើម្បីយាយីតាមរយៈប្រព័ន្ធតុលាការទៅលើគ្រប់ទម្រង់នៃការជំទាស់ ដូច្នេះការណ៍ដែលចៅក្រមធ្វើការសម្រេចដោយអព្យាក្រិតដូចក្នុងករណីនេះគឺមានតិចតួចបំផុត ។ ស្ថានភាពនេះគូសបញ្ជាក់ពីគ្រោះថ្នាក់ដែលបណ្តាលមកពីការកើនឡើងនូវលទ្ធភាពរបស់រដ្ឋាភិបាល និងការគ្រប់គ្រងលើមតិយោបល់ខាងនយោបាយនៅលើបណ្តាញអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា។

*<u>ករណីទី៩ ៖ ការព្រមានជាផ្លូវការកើតមាននៅប្រទេសកូរ៉េ</u>*

នៅដើមឆ្នាំ ២០១៤ ពលករចំណាកស្រុកខ្មែរចំនួន ៤ រូបបានថតសកម្មភាពដែលពួកគេដុតរូបថតរបស់លោក ហ៊ុន សែន និងបានផ្សព្វផ្សាយរូបភាពទាំងនេះនៅលើប្រព័ន្ធអ៊ីនធឺណិត ជាការឆ្លើយតបនឹងការបាញ់ប្រហារទៅលើអ្នកតវ៉ាចំនួនប្រាំរូបនៅផ្លូវវេងស្រេង នៅជាយក្រុងភ្នំពេញកាលពីខែមករាក្នុងឆ្នាំជាមួយគ្នានេះ។ ពួកគេបាននិយាយថា *"ងាប់ទៅ ហើយទៅចុះនរកទៅ។ នេះជាហេតុផលដែលឯងបញ្ជាទ័ពឱ្យសម្លាប់កម្មករ"*។[65] ឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសកូរ៉េខាងត្បូង លោក ស៊ុត ឌីណា បានស្នើឱ្យសាធារណៈជនជួយកំណត់អត្តសញ្ញាណពីបុគ្គលនោះ ដើម្បីនេះអាចចាត់វិធានការផ្លូវច្បាប់។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ឯកអគ្គរាជទូតបានលេចមុខនៅក្នុងវីដេអូឃ្លីបមួយដែលគាត់បានបង្ហោះលើបណ្តាញហ្វេសប៊ុកជាមួយនឹងមនុស្សទាំងបីរូបដែលបានឃើញក្នុងវីដេអូមុននោះបានសូមអភ័យទោសពីលោក ហ៊ុន សែន។ ករណីនេះបង្ហាញថានិន្នាការតាមដានអ្នកបញ្ចេញមតិយោបល់លើបណ្តាញសង្គមបានពង្រីកវិសាលភាពដល់ភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាល ថែមទាំងកំណត់មុខសញ្ញាពលរដ្ឋ ប្រជាជនកម្ពុជាដែលរស់ឯនៅបរទេស។ ករណីនេះបង្ហាញពីករណីរំលោភសិទ្ធិមនុស្សមួយក្នុងចំណោមករណីជាច្រើនទៀតនាពេលថ្មីៗនេះក្នុងប្រទេសកម្ពុជា ហើយក៏ជាការគួរឱ្យព្រួយបារម្ភផងដែរ។

*<u>ករណីទី១០ ៖ មន្ត្រីគណបក្សសង្គ្រោះជាតិត្រូវបានចោទប្រកាន់ដោយសារបង្ហោះសំបុត្រកំណើត</u>*

កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ នគរបាលបានចាប់ខ្លួនបុគ្គលពីររូបពាក់ព័ន្ធនឹងការបង្ហោះសំបុត្រកំណើតនៅលើបណ្តាញហ្វេសប៊ុកដែលថាខេត្តស្វាយរៀងស្ថិតក្នុងប្រទេសវៀតណាម។[66] សមាជិកក្រុមប្រឹក្សាក្រុងរបស់ គ.ស.ជ លោក នង សារិទ្ធ ត្រូវបានចោទប្រកាន់ពីការក្លែងឯកសារសាធារណៈ ហើយសកម្មជននៅ

---

[64] គុច ណារ៉េន " លោក ហ៊ុន ម៉ាណែត ដាក់ពាក្យបណ្តឹងចំពោះការបង្ហោះលើហ្វេសប៊ុក" សារព័ត៌មាន ខេមបូឌា ដេលី (ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1KoYRfC.

[65] ម៉ៃ ទិត្យថារ៉ា "កម្ពុជាស្នើឱ្យកូរ៉េខាងត្បូងជួយស្វែងរកក្រុមទំនើងជនជាតិខ្មែរ" សារព័ត៌មាន ខ្មែរថាម (ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦) អាចរកបានតាមរយៈ ៖ http://bit.ly/1KoWNEx

[66] ផាក់ ស៊ាងលី "សមាជិក គ.ស.ជ ពីររូបត្រូវបានដាក់ពន្ធនាគារដោយសារកុហករឿងសំបុត្រកំណើត" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/1W4FB8b.

មូលដ្ឋានរបស់ ក.ស.ជ លោក សុខ សំអ៊ាន ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋបន្ទាប់ពីលោកបានបង្ហោះរូបភាពសំបុត្រកំណើតនៅលើបណ្ដាញសង្គមហ្វេសប៊ុក។ យោងទៅលើប្រធាននគរបាលមូលដ្ឋានលោក ពិន ភីរម្យ បានបញ្ជាក់ថាការស្វែងរកបុគ្គលទាំងពីរនេះមានភាពងាយស្រួល ដោយសារ សំអ៊ាន ប្រើប្រាស់ឈ្មោះពិតរបស់ខ្លួនលើបណ្ដាញហ្វេសប៊ុក ដែលអាចរកគាត់ឃើញក្នុងអំឡុងពេលតែកន្លះម៉ោងប៉ុណ្ណោះ។ ការចោទប្រកាន់ហាក់បីដូចជាធ្វើឡើងដោយលក្ខណៈទូលំទូលាយទៅលើច្បាប់ព្រហ្មទណ្ឌ ដែលហាក់មិនច្បាស់លាស់ថាតើពួកគេព្យាយាមញុះញង់នរណា ហើយបទល្មើសអ្វីជាក់លាក់ដែលពួកគេព្យាយាមញុះញង់នោះ។ យោងទៅតាមមតិយោបល់ដែលមិនច្បាស់លាស់របស់ប្រធាននគរបាល លោក ពិន ភីរម្យ ការក្លែងបន្លំដែលបានចោទប្រកាន់នោះ *"ប៉ះពាល់ដល់សង្គម និងធ្វើឲ្យពិភពលោកមានការច្រលំ"*។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្នុងអំឡុងពេលប្រាំមួយខែកន្លងមកនេះ សិទ្ធិបច្ចេកវិទ្យា ជាក់ស្តែងសេរីភាពខាងការបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត បានក្លាយទៅជាឧបសគ្គឈានមុខគេក្នុងការការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ស្របពេលនឹងការរីកសាយភាយយ៉ាងឆាប់រហ័សការប្រើប្រាស់អ៊ីនធឺណិតទូទាំងប្រទេសកម្ពុជា ប្រជាពលរដ្ឋសាមញ្ញមានលទ្ធភាពទទួលបានព័ត៌មានដែលមិនធ្លាប់មានពីមុនមក ផ្តល់អំណាចដល់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងវិស័យនយោបាយដែលមិនធ្លាប់មានពីមុនមក។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរបច្ចេកវិទ្យាឆ្ពោះទៅរកការប្រើប្រាស់វេទិកាលើបណ្តាញអ៊ីនធឺណិតដើម្បីសំដែងមតិជំទាស់ រួមផ្សំនឹងសមត្ថភាពត្រួតពិនិត្យតាមដានថ្មីរបស់រដ្ឋាភិបាល បានធ្វើឲ្យប្រជាពលរដ្ឋរាប់លាននាក់ស្ថិតក្រោមការត្រួតពិនិត្យយ៉ាងល្អិតល្អន់ដោយផ្ទាល់ពីសំណាក់រដ្ឋាភិបាល ជាពិសេសបង្កើនសមត្ថភាពដល់អាជ្ញាធរដើម្បីយាយីតាមផ្លូវតុលាការដល់អ្នកដែលជំទាស់នឹងផលប្រយោជន៍រដ្ឋាភិបាល។ ការចង្អុលបង្ហាញពីខាងដើមពីរបៀបដែលរដ្ឋាភិបាល មានគោលបំណងប្រើប្រាស់លទ្ធភាពតាមដានប្រជាពលរដ្ឋគឺជាបញ្ហាដ៏អាប់អួរមួយ។ ការរកឃើញរបស់ ម.ស.ម.ក ពីការឃ្លាំមើលការរំលោភសិទ្ធិបច្ចេកវិទ្យា ក្នុងអំឡុងពេលប្រាំមួយខែឃើញថារដ្ឋាភិបាល និងនាយករដ្ឋមន្ត្រី មានគោលបំណងបង្កើនអំណាចក្នុងការបំបិទសំលេងរិះគន់។ អ្វីដែលជាការព្រួយបារម្ភនោះគឺនឹងបង្កជាគ្រោះថ្នាក់ពិតប្រាកដដែលនឹងឈានដល់ការបង្កើតវប្បធម៌នៃការដាក់ពិរុទ្ធខ្លួនឯង ក្នុងចំណោម*ប្រជាជនដែលប្រើប្រាស់អ៊ីនធឺណិត*មានការកើនឡើងនោះ។

បញ្ហាផ្លូវច្បាប់ដែលលេចចេញពីការឆ្ពោះទៅរកការសំដែងមតិលើបណ្តាញអ៊ីនធឺណិតមិនបង្ហាញពីភាពខ្មៅ និងសនោះទេ។ បញ្ហាបន្ទាន់បំផុតមួយដែលត្រូវធ្វើខណៈមានការផ្លាស់ប្តូរទាំងនេះ គឺទាមទារឲ្យរដ្ឋាភិបាល និងប្រព័ន្ធតុលាការកម្ពុជាក្នុងការបង្កើតវិធីសាស្ត្រសមហេតុផលមួយចំពោះការផ្តល់មតិយោបល់លើបណ្តាញអ៊ីនធឺណិត។ នៅក្នុងករណីមួយចំនួនដែលបានរៀបរាប់ក្នុងកំណត់ត្រាសង្ខេបនេះ បុគ្គលដែលប្រើប្រាស់អ៊ីនធឺណិតគឺជាអ្នកដែលបង្ហោះខ្លឹមសារមិនសមហេតុផល និងមិនត្រឹមត្រូវលើបណ្តាញអ៊ីនធឺណិតតែទោះជាយ៉ាងណាក៏ដោយ ការបង្ហោះទាំងនោះមិនគួរត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនោះទេនៅក្នុងសង្គមប្រជាធិ

បតេយ្យដ៏ល្អ។ ពាក់ព័ន្ធនឹងមតិយោបល់ដែលសំដៅលើបុគ្គលសាធារណៈ ច្បាប់សិទ្ធិមនុស្សអន្តរជាតិទាមទារឲ្យមានការអធ្យាស្រ័យច្រើនចំពោះការបញ្ចេញមតិពាក់ព័ន្ធនឹងមន្ត្រីសាធារណៈ ជាជាងការអនុវត្តដូចនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ។

ខណៈពេលដែលមានការប្រើប្រាស់ច្បាប់ដែលមានស្រាប់កន្លងមកក្នុងការកំណត់មុខសញ្ញាបុគ្គលដែលបង្ហោះខ្លឹមសារលើបណ្តាញអ៊ីនធឺណិត ការបង្កើតច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យាមិនត្រឹមតែធ្វើឱ្យមានការព្រួយបារម្ភនោះទេ ថែមទាំងវាមិនចាំបាច់ផងដែរ។ ជាជាងការបង្កើតច្បាប់ថ្មីដែលមិនស៊ីសង្វាក់ជាមួយនឹងការធានាសិទ្ធិមនុស្សថ្នាក់ជាតិ និងអន្តរជាតិ រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា នឹងត្រូវបានទទួលបានសេវាយុត្តិធម៌កាន់តែប្រសើរឡើង ប្រសិនបើប្រព័ន្ធតុលាការបានបណ្តុះបណ្តាលបានល្អពីការអនុវត្តច្បាប់ដែលមានស្រាប់ស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

នៅក្នុងបរិបទនៃស្ថានភាពដែលបានរៀបរាប់នៅក្នុងកំណត់ត្រាសង្ខេបនេះ ម.ស.ម.ក មានការបារម្ភយ៉ាងខ្លាំងពាក់ព័ន្ធនឹងស្ថានភាពនៃសិទ្ធិបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា និងសូមជូននូវអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលដូចខាងក្រោម៖

- *លុបចោលសេចក្តីស្នើច្បាប់ឧក្រិដ្ឋកម្មបច្ចេកវិទ្យា ដែលមិនត្រឹមតែមិនមានសង្គតភាពជាមួយនឹងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏មិនចាំបាច់ផងដែរ ដោយសារសកម្មភាពដែលច្បាប់នេះមានបំណងដាក់ទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌរួចជាស្រេចហើយ*
- *វិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីលុបបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ អោយស្របនឹងស្តង់ដារអន្តរជាតិ និងអនុសាសន៍នៃស្ថាប័នសិទ្ធិមនុស្សផ្សេងៗរបស់អង្គការសហប្រជាជាតិ*
- *វិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីកែប្រែប្បញ្ញត្តិណាដែលផ្ទុយនឹងការធានាលើសេរីភាពខាងការបញ្ចេញមតិដែលមានក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ។ ប្បញ្ញត្តិទាំងនេះរួមមាន ជាពិសេស មាត្រា ៤៩៥ (បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស) មាត្រា ៤៩៦ (បទញុះញង់ឲ្យមានអំពើហិង្សា) មាត្រា ៥០២ (ការជេរប្រមាថ) និងមាត្រា ៥២៣ (បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ) ដែលជាញឹកញយត្រូវបានអនុវត្តខុស និងផ្ទុយនឹងគោលការណ៍សិទ្ធិមនុស្ស ដែលនេះគួរតែត្រូវបានធ្វើវិសោធនកម្ម។*
- *ចាត់វិធានការក្នុងការគាំទ្រផ្លូវការទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ ការការពារ និងការទទួលបានសិទ្ធិមនុស្សលើបណ្តាញអ៊ីនធឺណិត*
- *ធានាថាប្រព័ន្ធយុត្តិធម៌កម្ពុជាធ្វើការត្រួតពិនិត្យដោយប្រុងប្រយ័ត្នលើការអនុវត្តឱ្យសមស្របនឹងការធានាសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាជាភាគី។ ជាពិសេសចៅក្រមថ្លឹងថ្លែងដោះស្រាយអោយបានអញ្ញាក្រិត លើតុល្យភាពរវាងសិទ្ធិសេរីភាពខាងការបញ្ចេញមតិនឹងសិទ្ធិផ្សេងទៀតនិងផលប្រយោជន៍សង្គម។*

- *បញ្ឈប់ការធ្វើទុកបុកម្នេញតាមផ្លូវតុលាការដល់សកម្មជននយោបាយ និងអ្នកនយោបាយបក្សជំទាស់ និងដោះលែង និងដោយគ្មានលក្ខខណ្ឌនូវអ្នកដែលបច្ចុប្បន្នត្រូវបានឃុំខ្លួនដោយការចោទប្រកាន់ ឬ ការកាត់ទោសក្រោមហេតុផលនយោបាយដែលមិនមានមូលដ្ឋានផ្លូវច្បាប់ និងមិនសមស្របនឹងលទ្ធិប្រជាធិបតេយ្យសេរី*
- *បញ្ឈប់ការប្រើប្រាស់ឥទ្ធិពលនយោបាយលើប្រព័ន្ធតុលាការ និងផ្តល់ដំបូន្មានដល់មន្ត្រីសាធារណៈឲ្យមានការអត់ធ្មត់ មុនពេលដាក់ពាក្យបណ្តឹងលើបុគ្គលដែលបានសរសេរិះគន់ខ្លួន ។*

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពជាមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ +៨៥៥ (០) ១៧ ៥២៨ ០២១ ឬអ៊ីម៉ែល chhunly.chhay@cchrcambodia.org ឬ លោក ផាត ដឺប្រូន ទីប្រឹក្សាច្បាប់ ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ +៨៥៥ (០) ៨៩ ៥៣៦ ២១៥ ឬអ៊ីម៉ែល pat.debrun@cchrcambodia.org។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

BY NC SA